01

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និង អក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ លោក ភិយ-ប៊ុក
ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកសាសនាៈ ព្រះទេពសត្ថា សួរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក ថែម | ព្រះរាជក្រិត្យ ក្រមទសករិយា ............ | ៥៦១ |
| លោក ផេង-ផ្រៃ សាស្ត្រាចារ្យ | បក្សីចិត្ត រឿងព្រេងប្រទេសរ៉ូម៉ានី ....... | ៥៧៣ |
| គណៈកម្មការវប្បធម៌ | ស័ព្ទបារាំងប្រែជាខ្មែរ ញ៉ុក-ថែម រួបរួម (តទៅ) | ៥៨១ |
| លោកសាង-សាភិត លេខានុការ | រឿងព្រេងភូមា (តមក).................. | ៥៨៥ |
| អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន | រឿងសាមកុក (តមក).................. | ៥៩៣ |
| — ទេពពិទូរ ឈឹម-ក្រសេម | ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក) ...... | ៦០០ |
| គណៈកម្មការទំនៀមទម្លាប់ខ្មែរ | សាវតារវត្តបាធយ មេឃុំ ឌួង-អ៊ួច តែង (ត-ចប់). | ៦០៥ |
| លោកប៉ុខ-ជាន់អតីតតំណាងរាស្ត្រ | គតិបណ្ឌិត ...................... | ៦១១ |
| **ផ្នែកសាសនា** | | |
| លោក ភិយ-ប៊ុក ក្រមការ | ពន្លឺអាស៊ីទ្វីប (តមក) .................. | ៦១៩ |
| ព្រះទេពមុនី យូរ-ប៊ុណ្ណ | ពលកថា (ត-ចប់) .................. | ៦២២ |
| យុវបណ្ឌានុរក្ស ប៊ូ-ប៊ូ | អម្ពជាតក ...................... | ៦២៩ |
| **កំណត់ទិនប្រវត្តិការណ៍** | | |
| ព្រះគ្រូសិរីសោភ័ណ ភិម-គូ | ពិធីដង្ហែដំណើរសម្តេចសង្ឃនាយក ដែលនិមន្តទៅលង្កាទ្វីប ...................... | ៦៣៣ |
| ក្រសួងធម្មការ | បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី (តមក) .. | ៦៣៩ |

ឆ្នាំទី ២២ – លេខ ៨ ខែសីហា ឆ្នាំ ១៩៥១ – ដំឡៃជាវ ១ ឆ្នាំ ១៤៥ រៀល ។

Revue religieuse et littéraire éditée par l'Institut Bouddhique

Rédacteur en chef de la partie littéraire : M. Ray-Buc
Kramakar à l'Institut Bouddhique.
Rédacteur en chef de la partie religieuse : Vénérable
Brah Déba Sattha So-Hay membre de la Commission du Tripitaka

# TABLE DES MATIÈRES

## Partie littéraire :

| | | pages |
|---|---|---|
| Luong Nibandhamantri Nhok-Thèm | Edit royal : Kramadasabhariyâ..... | 56 |
| M. Pheng-Chrieu, Professeur au Collège des jeunes filles | L'oiseau du paradis (Conte roumain) | 57 |
| Commission Culturelle | Mots traduits par la commission Culturelle et recueillis par M. Nhok-Thèm (suite)........................ | 58 |
| M. Sang-Savath, Secrétaire Ministère des Finances | Contes birmans (suite)............ | 58 |
| Neak Oknha Vibularajaséna Nou-Kân | Histoire de SAMKOK (suite)........ | 59 |
| Neak Oknha Debabidura Chhim-Krasem | Histoire du Royaume du Cambodge (suite)...................................... | 60 |
| Commission des Mœurs et Coutumes | Notice historique de la pagode de Banoi (Angkanh-Takéo) par le Mékhum Duong-Ouch (suite et fin).......... | 60 |
| M. Bun-Than ancien député | L'opinion d'un Sage.............. | 61 |

## Partie religieuse :

| | | |
|---|---|---|
| M. Ray-Buc Kramakar (I.B.) | Lumière de l'Asie (suite) ........ | 61 |
| Préah Debamuni You-Fonn | Balakathâ (suite et fin) ........... | 62 |
| Khun Pannanurak Bou-Po | Amba jâtaka ........................ | 62 |

## Notes et chroniques

| | | |
|---|---|---|
| Brah Krou Sirisobhana Kem-To | Départ de Samdech Brah Moha Sumédhadhipati, Chef de secte pour Colombo (Ceylan)...................... | 63 |
| Ministère des Cultes | Nomination des nouveaux Chau-Adhikar (suite) ................ | 63 |

# ព្រះរាជក្រឹត្យ

# ក្រមទសភរិយា

ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះជ័យចេស្តា (ចៅពញាសួរ) គ. ស. ១៦៩៣

## ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម រួបរួម

## ពាក្យផ្តើម

ព្រះរាជក្រឹត្យ ក្រមទសភរិយានេះ កើតឡើងក្នុងរជ្ជកាលព្រះបាទសម្តេចព្រះជ័យចេស្តា ( ចៅពញាសួរ ) ក្នុងឆ្នាំជាមួយនឹងក្រមពលទេព នឹងក្រមដទៃៗទៀតជាច្រើន ខុសគ្នាតែថ្ងៃ-ខែ គឺក្រមទសភរិយានេះ គេបានរៀបរៀងប្តូររួបរួមចម្លង នៅថ្ងៃអាទិត្យខែបុស្សឆ្នាំមមែ ៗ ឯក្រមពលទេព គេបានរៀបរៀងប្តូរស្រង់ចម្លង នៅថ្ងៃចន្ទ ៣ កើតខែកត្តិកឆ្នាំមមែ ក្នុងកម្ពុជមហាសករាជ ១៦១៥ ដូចគ្នា ៗ ឯសេចក្តីសារសព្វក្រៅអំពីនេះ យើងបានពោលរួចមកហើយក្នុងក្រមពលទេពឯណោះ ៗ

ពាក្យថា "ក្រមទសភរិយា" ប្រែថា "ច្បាប់សម្រាប់ភរិយា ១០ ជំពូក" បានដល់ភរិយាដូចម្តេចខ្លះ ច្បាប់ដើមមិនបានពោលទុកដោយច្បាស់លាស់ឡើយ មាននិយាយតែពីច្បាប់លក់ពិន័យប្រុស-ស្រីប្តីប្រពន្ធ-សហាយស្មន់អន្ទូករ-អាពុកម្តាយ ដូចជាលក់ពិន័យប្តីប្រពន្ធដែលបានគ្នាហើយលះលែងគ្នាវិញ-លក់ពិន័យប្រុសស្រីដែលសហាយគ្នាហើយលះលែងគ្នាវិញ-លក់ពិន័យខ្ញុំនាំដំរត់កូនក្រមុំគេ-លក់ពិន័យអ្នក

ផងនាំជាតិស្រុកពួនគេ – លក់ពិន័យក្រមុំកម្លោះសហាយគ្នា – លក់ពិន័យ
ពុកម្តាយខាងប្រុសនិងកូនប្រុស អំពីដំណើរកូនក្រមុំគេរត់មកនៅជា
មួយនឹងកូនប្រុសរបស់ខ្លួន – លក់ពិន័យអ្នកជាទៅសហាយនឹងខ្ញុំគេ –
លក់ពិន័យអ្នកដាក់ស្នេហ៍កូនក្រមុំគេ – លក់ពិន័យកូនប្រុសដែលទៅ
សហាយនឹងកូនក្រមុំគេ បានហើយលះលែងចោល – លក់ពិន័យខ្ញុំគេ
នឹងខ្ញុំគេបានគ្នាហើយលះលែងគ្នា ។ល។ ដូច្នេះជាដើម មិនមានរៀប
កប់ចេញឈ្មោះទោសករិយាសោះឡើយ ។ តាមទំនងនេះ នាំឲ្យយើង
យល់ថា តាមច្បាប់ជាន់ដើមនោះ មិនមានធ្វើទោសដាក់គុកឃុំខាំង
មានកំណត់ ខែ-ឆ្នាំ នឹង បង្ខំឲ្យធ្វើការដូចសព្វថ្ងៃនេះទេ, វៀរលែងតែ
មានទោសជាឧក្រិដ្ឋ ដូចជាសម្លាប់គេដោយអាឃាតព្យាបាទជាដើម
ទើបត្រូវសម្លាប់តែម្តង ។ ក្រៅអំពីនេះច្រើនតែធ្វើទោសដាក់ខ្នោះប្រក-
ឃ្នាងនឹងកយផ្ទាលបណ្តើរគោក្រោស ឬលក់ពិន័យតិចច្រើនតាមទោសា-
នុទោស ដូចពោលមកហើយ ។

៦សំដីពាក្យពេចន៍ ក្នុងក្រមទោសករិយានេះ មានពាក្យក្រៗ ជា
ច្រើនអន្លើ ។ ការចម្លងចេញមកនេះ គង់មានភ្លាំងភ្លាត់មិនខានទេ
ដ្បិតច្បាប់សាស្ត្រាស្លឹករឹតនោះ មានវិបត្តិអក្ខរនិងសេចក្តីជាច្រើនអន្លើ
ដោយការចារចម្លងរើរុះមកជាច្រើនតំណ ។ មួយវិញទៀត បើទុកជា
យើងបានធ្វើនយលក្ខណៈ ដើម្បីពន្យល់ពាក្យនិងសេចក្តីក្រៗ ទុកជា

ច្រើនអន្លើ ក៏គង់តែមិនសព្វគ្រប់ទេ បើនៅមានសេចក្តីភ្លាំងភ្លាត់ខ្លះ យើងសូមអភ័យទោសអំពីលោក អ្នកមើលក្រមនេះក្នុងឱកាសនេះផង ។

នៅទីបំផុត បើទុកជាក្រមទសកិរិយានេះ មិនមានប្រយោជន៍ជាសាធារណ៍ដល់អ្នកមើលទូទៅ ក្នុងជំនាន់ឥឡូវនេះ ព្រោះជាច្បាប់កន្លងកាលសម័យមកយូរហើយ នឹងប្រកាន់យកជាច្បាប់សម្រាប់ប្រើការក្នុងសម័យនេះពុំបានឡើយ ក៏គង់តែមានប្រយោជន៍បានខ្លះ ដល់ក្បួនច្បាប់អក្សរសាស្ត្រ នឹងជាប្រយោជន៍បានខ្លះ ដល់អស់លោកអ្នកដែលចង់ចេះចង់ដឹងក្បួនច្បាប់ចាស់ ៗ នឹងរបៀបពាក្យពេចន៍សំដីវោហារជាន់ដើម ។ ដ្បិតការចម្លងចេញបោះពុម្ពនេះ យើងបានរក្សាទុកនូវពាក្យពេចន៍សំនួនវោហារតាមច្បាប់ដើមទាំងអស់ មិនបានកែប្រែសម្រួលទៅតាមកាលសម័យឡើយ ។

មួយវិញទៀត ព្រះរាជក្រិត្យ ក្រមទសកិរិយានេះ នៅខាងចុងបញ្ចប់ដាក់ថា "នេះច្បាប់ទសកិរិយា អ្នកឧកញ៉ាពិភក្តិសេនីចារចប់នៅថ្ងៃ ៦ កើតខែពិសាខ ឆ្នាំថោះនក្ស័ត្រឯកស័ក[២០]" ។ ដូច្នេះ មានដាក់បញ្ជាក់តែថ្ងៃ -ខែ- ឆ្នាំ ដែលបានចារចម្លងចប់ គ្មានដាក់សករាជបញ្ជាក់ឲ្យដឹងទេ ប៉ុន្តែមានដាក់លេខ ២០ លើពាក្យថា "ឯកស័ក[២០]" សឲ្យដឹងថា នៅក្នុងកម្ពុជរដ្ឋកាលណាមួយ ដែលមានស្តេចគ្រងរាជ្យកន្លងទៅបានគំរប់ទី ២០ វស្សា ។ តាមទំនងនេះ ប្រហែលជានៅក្នុងកម្ពុជ

រជ្ជកាល ព្រះបាទសម្តេចព្រះនរោត្តមព្រហ្មបរិរក្ស (ព្រះករុណាសុវណ្ណកោដ្ឋ) ព្រោះប្រការ ១) ព្រះរាជាក្សត្រអង្គនេះ ទ្រង់រាជ-សម្បត្តិជាយូរអង្វែងដល់ ៥២ វស្សា, ២) ទ្រង់ឡើងគ្រងរាជសម្បត្តិក្នុងឆ្នាំវក ទោស័ក ពុទ្ធសករាជ ២៤០៣ បើគិតតាំងពីឆ្នាំនេះ រហូតដល់គំរប់ឆ្នាំទី ២០ ក្នុងរាជសម្បត្តិ ឃើញថាត្រូវនឹងឆ្នាំថោះឯកស័ក ពុទ្ធសករាជ ២៤២២ ហើយ, ៣) ចំណាស់របស់ស្លឹករឹតនោះប្រហែលមានអាយុដល់ ៦០ – ៧០ ឆ្នាំហើយ (បើគិតតាំងពីឆ្នាំទី ២០ ក្នុងរជ្ជកាលនោះ រហូតមកដល់ឆ្នាំនេះ ព. ស. ២៤៨៧ ជារយៈវេលាដល់ ៦៤ ឆ្នាំ ឃើញថាសមនឹងចំណាស់របស់ស្លឹករឹត) ។ ហេតុដូច្នេះ ទើបគួរយល់ថាព្រះរាជ-ក្រឹត្យ ក្រមទសករិយានេះ ប្រាកដជាអ្នកចុះកញ្ចាំពិភក្តិសេនីបានចារចម្លងចប់នៅក្នុងថ្ងៃ ៦ កើតខែពិសាខ ឆ្នាំថោះឯកស័ក ២០ ពុទ្ធសករាជ ២៤២២ ក្នុងរជ្ជកាលនោះឯង ។

ពុទ្ធសាសនបណ្ឌិត្យថ្ងៃ ១១ សេបតមប្រ៍ ១៩៤៤

ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថែម

# ព្រះរាជក្រឹត្យ

# ក្រមទសភរិយា

ក្នុងរជ្ជកាល ព្រះបាទសម្ដេចព្រះជ័យជេស្ឋា (ព. ស. ១៦៤៣)

---

សុភមស្តុស្វស្តិ សុភមង្គលពហុលចេស្តាជយាតិរេក ១៦១៨ ស័ក ខែចេត្រ[1] បុស្សមាសា អាទិត្យពារនាមន្តិ[2] ព្រះបាទសម្ដេចនរនាថ ព្រះបរមបពិត្រ អ្នកជាអម្ចាស់ស្ដេចគង់ព្រះរាជមន្ទីរបុរីបរមាល័យ ស្ដេចមានព្រះរាជឱង្ការ បើកព្រះបន្ទូលមធុរព្រះតម្រាស់ត្រាស់លើត្បូង ឧកញ៉ាសុភាធិបតី បរិក្សពិភក្ដិក្រឡាប្រាក្រមស្ដុកពាហុ ឲ្យធ្វើជាមាត្រាច្បាប់ប្រញប្តិ ចំពូមក្រឡាពាសមរជកខុនវែលងឲ្យចេញមកដល់ព្រះវង្ស នូវរាជវង្សានុវង្ស នូវរាជគ្រូបុរោហិត នូវអស់នាហ្មឺនមុខមន្ត្រី ករបណ្ឌិត ព្រឹទ្ធាចារ្យ នូវអស់ចៅហ្វាយស្រុក នៅលំនៅខេត្តខណ្ឌផង ទាំងពួង ឲ្យបានដឹងក្នុងព្រះមាត្រាច្បាប់នេះ កុំឲ្យរំដួលចិត្តក្រោដ្ឋកើតកោលាហល កន្លល់ក្ដៅក្រហាយក្នុងផ្ទៃក្រោមឡើយ ឲ្យបានក្សេមក្សាន្តអស់ចិត្តអាណាប្រជានុរាស្ត្រផង នាក់ឡុងផ្ទៃក្រោមនេះ ។ ទើបព្រះបាទអ្នកជាអម្ចាស់ត្រាស់បើកព្រះអំណាចឲ្យឧកញ៉ាសុភាធិបតី ជាមាត់ផ្ទៃក្រោម ឲ្យស្រដី

---

១ ត្រង់ពាក្យថា "១៦១៨ ស័ក ខែចេត្រ" គឺមហាសករាជ ១៦១៨ ឆ្នាំខែចេត្រ

២ ពាក្យថា "បុស្សមាសា អាទិត្យពារនាមន្តិ" គឺខែបុស្សថ្ងៃអាទិត្យ នាដិតិ ។

មុខរាជការសារពើដំនុំសេចក្ដីយកខ្វាត់អបករណ៍ (១) ចូលជាដង្វាយថ្វាយព្រះបាទអ្នកជាម្ចាស់ច្បាស់ដោយនូវព្រះមាត្រាពោះនេះ (២)

មាត្រា ១ ទោះយោបកដវង្សស្រុកផ្ការ ឧកញ៉ា, ពញា, ព្រះដី, ចៅហ្មឺន, មានងារ, ឥតងារ, នូវអាណាប្រជានុរាស្ត្រទាសការក្មួយពារ៍ ខ្មែរ ចិន ចាម ជ្វា បារាំង យួន សៀម មន តួន បារគូបុរោហិត ពល អ្នកងារ អ្នកជា ខ្ញុំគេ មហាតបាទត្រា ពលព្រះកញ្ចះព្រះសង្ឃបំពេស ពោសព្រាសឲ្យបានដឹងក្នុងព្រះរាជក្រឹត្យច្បាប់នេះ កុំឲ្យអាណាប្រជានុរាស្ត្រផង កន្លងរំលងនឹងព្រះរាជក្រឹត្យនេះឡើយ ។

មាត្រា ១ សោត ខ្ញុំអ្នកជងឲ្យទៅដណ្ដឹងកូនក្រមុំគេយកជាប្រពន្ធ មានក្រាបសំពះមេបាជាស្រេចការហើយ បើប្រលែងលែងគ្នាវិញនោះ ឲ្យចៅពញាជាខុនក្នាក់ងារខុនលែង ហូតយកខ្វាត់តម្លឹង ៦ កំបាន តម្លឹង ៣ កំបាន និមួយតួ នូវដើងកោះស៊ីង ១ និមួយតួហោង ។

មាត្រា ១ សោត បើប្រពន្ធស៊ីស្វាធីកកំណត់ហើយ បើប្រលែងលែងគ្នាវិញ ឲ្យយកខ្វាត់តម្លឹង ៣ កំបាន បាទ ១០ កំបាននិមួយតួ នូវដើងកោះស៊ីង ១០ និមួយតួហោង ។

---

១ ពាក្យថា "អបករណ៍" តាមរូបស័ព្ទប្រែថា ដំណើរប្រាសចាកអំពើ គឺការធ្វើមិនល្អ, អំពើពុំប្រសើរ, ការធ្វើខុស ។ តែក្នុងទីនេះ ពាក្យថា "យកខ្វាត់អបករណ៍" សំដៅការយកពន្ធដាក់ព្រះឃ្លាំងព្រះរាជទ្រព្យ ចំពោះបុរសស្ត្រីដែលធ្វើខុសនឹងព្រះរាជប្រិញ្ញប្ដិរបស់ព្រះមហាក្សត្រដូចមានសេចក្ដីសារស័ព្ទក្នុងផ្ទៃរឿងខាងក្រោមនេះស្រាប ។ ២. មាត្រាពោះនេះ គឺមាត្រាផ្ទៃពោះ ឬមាត្រាផ្ទៃចតទៅនេះ ។

មាត្រា ១ សោត បើប្រពន្ធបានស៊ីស្វាថង់វង់ហើយ ប្រលែងលែងគ្នាវិញ ឲ្យខុនភ្នាក់ងារហូតយកខ្នាត់បាទ ១០ ក៏បាន បាទ ៦ ក៏បាន ដើងកោះស៊ឹង ១០ និមួយគូហោង ។

មាត្រា ១ សោត បើប្រពន្ធស៊ីស្វាម្ចាវទេ បើ ( ប្រលែង ) លែងគ្នាវិញ ឲ្យខុនភ្នាក់ងារហូតយកខ្នាត់បាទ ៦ ក៏បាន បាទ ៣ ក៏បាន ដើងកោះស៊ឹង ១០ និមួយខ្លួនហោង ។

មាត្រា ១ សោត បើអ្នកផងជាអន្ទករ[១] ផងគ្នា បានសំពះខ្មោចមេបាហើយប្រលែងលែងគ្នាវិញ ឲ្យហូតយកខ្នាត់បាទ ៦ ដើងកោះស៊ឹង ១០ និមួយគូហោង ។

មាត្រា ១ សោត នរអ្នកផងជាស្ទូនអន្ទករនឹងគ្នាហើយលែងគ្នាវិញ ឲ្យហូតយកខ្នាត់បាទ ៣ ដើងកោះស៊ឹង ១០ និមួយគូហោង ។ លាងខ្មាសបាទ ៦ ក៏បាន បាទ ៣ ក៏បានហោង ។

មាត្រា ១ សោត ទោះបីអ្នកផងនាំម្រត់ ( ជំរត់, ពង្រត់ ) ខ្ញុំគេ ទោះប្រុសក្តី ស្រីក្តី ទោះនាំម្រត់ទៅលក់ក្តី នាំម្រត់ទៅយកជាប្រពន្ធក្តី ឲ្យពិន័យអាប្រុសនាំម្រត់ខ្ញុំគេជាប្រាក់តម្លឹង ៣០ មេស្រីខ្ញុំគេតម្លឹង ១២ ដើងកោះបាទ ៥ ដើងកោះអាប្រុសនាំម្រត់ស៊ឹង ១០ ហោង ។

---

១ អន្ទករ មកពី អន្ទះ "ងងឹត, ខ្វាក់" + ករះ "ធ្វើ" > អន្ទករះ "ធ្វើឲ្យងងឹត, ធ្វើឲ្យខ្វាក់" មានសេចក្តីថា លួចលាក់ធ្វើកិច្ចនោះក្នុងទីកំបាំងភ្នែកអ្នកផង ត្រូវនឹងសំដីសព្វថ្ងៃនេះហៅថា សហាយ ច្រើននិយាយថា សហាយស្មន់អន្ទករ ។

មាត្រា ១ សោត បើខ្ញុំគេនាំម្រត់អ្នកជាក្តី កូនក្រមុំគេក្តី បើចាប់បាន ឲ្យទៅប្រាប់អម្ចាស់ ហើយឲ្យពិន័យគាប្រុសចោរនូវមេស្រីចោរនោះដាច់ស្បូវលទិមួយៗ គួ ឲ្យប្រាណក៏ទឹកដោះមេស្រី ( ម្តាយ ) តម្លឹង ៥ ឲ្យទៅពញាជាខុនភ្នាក់ងារហូតយកខ្វាត់ព្រះឃ្លាំងពុះគ្រឹង[១] និមួយៗគួហោង ៗ

មាត្រា ១ សោត បើអ្នកឯណានាំម្រត់ប្រពន្ធគេ ( ដែល ) បាន រៀបការសំពះខ្មោច ដាច់សត្វជើង ២ ជើង ៤ ក្តី[២] ឲ្យពិន័យប្រុសតម្លឹង ១២ ស្រីតម្លឹង ៥ ឲ្យហូតយកខ្វាត់បាទ ១០ និមួយខ្លួន ខ្វាត់ព្រះឃ្លាំង តម្លឹង ៦ ជើងកោះស៊ឹង ១០ និមួយខ្លួនហោង ៗ

មាត្រា ១ សោត បើប្រពន្ធបានក្រាបក្បាលសំពះមេបាម្តាយអា-ពុកក្តី ទោះបីបានក្រាបថ្វាយបង្គំព្រះបាទអ្នកជាអម្ចាស់ក្តី ទោះសំពះ ១០ ហូពាន់ក្តី ៨ ហូពាន់ក្តី ៦ ហូពាន់ក្តី បើឈ្មោះគ្នាហើយ បានប្តឹងទៅក្រមឲ្យជំនុំផ្តាច់ចេញហើយ ឲ្យខុនភ្នាក់ងារហូតយកខ្វាត់តម្លឹង ៦ នូវជើងកោះស៊ឹង ១០ និមួយគួ ៗ ឯរបស់សម្លាប់តាំងប៉ុន្មានៗ ឲ្យទៅពញាជាខុនភ្នាក់ងារនូវព្រះសុភាជំនុំចែក ហើយឲ្យហូតយកថ្លៃរបស់តាំងនេះ តាមដម្លៃរបស់ប៉ុន្មានៗ ( ចំនួន ) ១០ ឲ្យយក ១ . . . . ៗ

---

១ ពុះគ្រឹង គឺពុះយកតែពាក់កណ្តាលហូតយកខ្វាត់ដាក់ព្រះឃ្លាំង ។ ២ គឺនៅកាលរៀបការសំពះខ្មោចមេបានោះ គេបានទិញឬសម្លាប់សត្វជើង ២ ដូចមាន់ទាជាដើម និងសត្វជើង ៤ មានជ្រូកគោជាដើម ។

. . . . . បើទោសសេចក្ដីឯណា ៗ ដល់ជាត្រូវបែអស់របស់ទ្រព្យ បើចៅក្រមជំនុំផ្ដាច់ឯងក្ដី ចែករបស់ទ្រព្យឯងក្ដី នោះជាបំបាំងបាត់មុខងារ អ្នកនគរញ៉ាសុភាធិបតី ឯខ្នាតជំនុំអ្នកឲ្យលំនៅនោះ ឲ្យក្រយាពិន័យភាគ ១០ ឯអាចោរមេចោរនោះ ត្រូវឲ្យក្រយាពិន័យផ្ដាច់សុរិលហោង[1] ៗ ឲ្យប្រណាំទឹកដោះតម្លឹង ៤ និមួយគូ ហើយឲ្យទៅចៅពញាជាខុនភ្នាក់ងារយកខ្នាតព្រះឃ្នាំងពុះគ្រឹង និមួយគូហោង ៗ

មាត្រា ១ ទោះបីអ្នកផងទៅស្នូនអន្ទករទឹងកូនក្រមុំគេ ហើយម្ដាយអាពុកមាក្មេបងប្អូនឯប្រុស ឲ្យទៅដណ្ដឹងម្ដាយអាពុកឯស្រីនោះគេពុំព្រមឲ្យជាប្រពន្ធកូនឯងនោះឡើយ ៗ ទោះចិត្តស្រីនឹងប្រុសនោះវាស្រឡាញ់គ្នាវាហើយ ស្រីវារត់ទៅនឹងប្រុសទៅ (នៅ) នឹងអាពុក (ម្ដាយ) ប្រុសនោះ ព្រះក្រិត្យដីកាថាឲ្យអាប្រុសនៅម្ដាយអាពុកអាប្រុស ជាអន្ទករទឹងកូនក្រមុំគេ នឹងកូននឹងប្រពន្ធគេ ទោះបើចាប់បានក្ដី ចាប់ពុំបានក្ដី វារត់រួចក្ដី នោះឲ្យប្ដឹងចៅក្រមឲ្យទៅចាប់ធ្វើក្ដីឲ្យកត់ពាក្យ បើអាចោរមេចោរវាឆ្លើយថាលួចមែន ចោរមែន គួរជំនុំកេមេតន្ទាប់គ្រប់តន្ទាប់ ឃើញហើយឲ្យកាត់ក្រយាពិន័យ អាចោរនូវមេចោរផ្ដាច់សុរិល ឯមេអណ្ដើកមេនាំការប្រពន្ធគេ កូនក្រមុំគេនោះ (ឲ្យពិន័យជាប្រាក់)

---

១ – មាត្រានេះស្ដាប់ចាប់យកសេចក្ដីពុំទាន់ច្បាស់ ប្រហែលជាមានបាត់សេចក្ដីជាច្រើនឃ្លា ច្រើនអក្សរ ៗ

តម្លឹង ១៥ ហើយឲ្យទៅភញាណាខុនភ្នាក់ងារហូតយកខ្វាត់ព្រះយ៉ាំងពុះត្រឹង ឯប្រពន្ធនោះបើប្តីស្រឡាញ់ខឹងយកជាប្រពន្ធវិញបានហោង ឲ្យបង់តែខ្វាត់តម្លឹង ៦ បាទ ២ ខុរដើងកោះស្ពឹង ១០ និមួយៗ តួឲ្យខុនភ្នាក់ងារហោង ។

មាត្រា ១ (សោត) ភរកម្មោះនឹងក្រមុំជាអន្តករទឹងគ្នាហើយនាំម្រត់ទៅពឹងពាក់សំណាក់នៅខុកញ៉ា ព្រះពញា ហ៊ុន នូវមេស្រុក នូវសាច់ញាតិបងប្អូនដីទៅព្រៀង (លាន) នោះ ព្រះក្រិត្យដីកាឲ្យពិន័យកុំឲ្យបង្គាប់ការឡើយ មានតែប្រាក់ខាន់ស្លាតិចច្រើនប៉ុន្មានៗ ក្តី បើប្រាប់ទៅពញា ជាខុនភ្នាក់ងារ ឲ្យហូតយកខ្វាត់តម្លឹង ៣ និមួយតួ ដើងកោះស្ពឹង ១០ និមួយតួ ។ បើពុំបានប្រាប់ភ្នាក់ងារស្រុក នូវទៅពញាជាខុនភ្នាក់ងារ ទុកជាម្តាយឪពុកមេស្រីនោះបំបាំងខ្វាត់ព្រះយ៉ាំងទុកញ៉ាសុភាធិបតី ឲ្យពិន័យជាប្រាក់ជឹង ៣ តម្លឹង ១៧ (១) កុំឲ្យប្រាណីឡើយ ។ ឯប្រាក់ខាន់ស្លានោះឲ្យហូតយកពុះត្រឹង តាមដោយតិចច្រើននោះឯង ឯអាពោនូវមេពោរនោះ ទុកជានាំម្រត់កូនក្រមុំគេហោង ដ្បិតពុំបានជូនកូនក្រមុំគេឲ្យពិន័យជាត្រីគុណហោង ។ បើប្រាប់ខុនភ្នាក់ងារឲ្យហូតយកខ្វាត់តម្លឹង ៣ ដើងកោះស្ពឹង ១០ និមួយខ្ទួន ឯអាពុកម្តាយអាប្រុស

---

១ ពាក្យថា ជីងឬតម្លឹង ជាមាត្រាប្រាក់បូរាណ បើគិតតាមមាត្រាប្រាក់សៀម ក្នុង ១ ជញ្ជីង មានទំងន់ ៨០ បាទ, ៣ ជញ្ជីង ត្រូវជា ២៤០ បាទ ។ ឯតម្លឹងមានទំងន់ ៤ បាទ ១៧ តម្លឹង ត្រូវជា ៦៨ បាទ ។ ហេតុនេះ ជីង ៣ តម្លឹង ១៧ ត្រូវជា ៣០៨ បាទ ។

ដែលឲ្យលំនៅមេស្រីទូវអាប្រុស ដែលពុំបានយកទៅជូនម្ដាយអាពុកស្រីនោះឡើយ ឲ្យពិន័យម្ដាយអាពុកពុំបានជូនកូនក្រមុំគេ ជាប្រាក់តម្លឹង ១៤ និមួយតួ នូវដើងកោះស្លឹង ១០ និមួយតួហោង ៗ បើអាពុកម្ដាយអាប្រុសបានជូនកូនក្រមុំគេហើយ ឥតទោសឡើយ ឲ្យចៅពញាជាខុនក្លាក់ងារហូតយកតែខ្វាត់បាទ ៦ ដើងកោះស្លឹង ១០ និមួយតួហោង ៗ បើលែងគ្នា ហូតយកខ្វាត់តម្លឹង ៣ និមួយខ្លួន ដើងកោះស្លឹង ១១ និមួយតួហោង ៗ បើចិត្តប្រុសស្រឡាញ់ (ស្រី) នោះឲ្យដណ្ដឹងម្ដាយអាពុកឯស្រីនោះដើង ១ ដើង ២ ដើង ៣ បើម្ដាយអាពុកពុំឲ្យកូននោះជាប្រពន្ធប្រុសនោះឡើយ បើចិត្តប្រុសនោះវាអាល័យស្រីនោះវាទៅតាមគ្នាវានោះបើពុំរាប់កូនឡើយឲ្យភាគខាន់ស្លាជាប្រាក់ដើង ៣ ស្លាសំពះ ៣ រូប ហើយឲ្យចៅពញាជាខុនក្លាក់ងារ យកខ្វាត់ព្រះឃ្មាំងពុះគ្រឹងហោង ៗ តែបានប្រាប់ក្លាក់ងារស្រុក នូវក្លាក់ងារជាខុនក្លាក់ងារឲ្យបានដឹងផង បើពុំបានប្រាប់ ទុកជាបំបាំងខ្វាត់ព្រះឃ្មាំងព្រះរាជទ្រព្យ ឲ្យពិន័យអាពុកម្ដាយទាំងសងខាង ជាប្រាក់ដើង ៣ តម្លឹង ១៧ និមួយតួហោង ៗ

មាត្រា ១ សោត មេស្រីនោះវារត់ទៅនៅនឹងប្រុស នឹងម្ដាយអាពុកប្រុសនោះ ដល់ថ្ងៃ ១ ថ្ងៃ ២ ថ្ងៃ ៣ ម្ដាយអាពុកប្រុសនោះពុំបានយកកូនស្រីគេទៅជូនម្ដាយអាពុកឯស្រីនោះឡើយ ពុំរៀបការសំពះគេឡើយ (បើ) ប្រាកដដូច្នោះ ឲ្យពិន័យអាពុកទាំងតួប្រុសជាច់សុរិលហោង ៗ

ហើយឲ្យចៅពញាជាខុនក្នាក់ង៉ារយក (ខ្វាត់) ព្រះយាំងពុះគ្រឹង ឯអាពុកម្តាយមេស្រីនោះទុកជាបំបាំងព្រះរាជទ្រព្យឲ្យពិន័យជាប្រាក់ដីង ៣ តម្លឹង ១៧ ឲ្យប្រណីទឹកដោះតម្លឹង ១៥ ហោង ។

មាត្រា ១ សោត ទោះអ្នកដងទៅស្ទូនអន្ទករទឹងខ្ញុំគេ ពុំបានកូនក្តី បើបានកូន ១ ក្តី បានកូន ២ ក្តី អាប្រុសនោះលែងវិញ ឲ្យពិន័យជាប្រាក់ ទុកជាអាប្រុសនោះ លួចកូនក្រមុំគេ តម្លឹង ៤៥ ឯកូននោះឲ្យបើកយក តែកំឡាំងតម្លឹង ៥ និមួយខ្លួន លាងខ្នាសបាទ ៦ ឲ្យយកខ្វាត់ព្រះយាំង អំពីអាប្រុសនោះ តម្លឹង ៦ បាទ ១ ដើងកោះបាទ ១ និមួយគួហោង ។ បើខ្ញុំគេទៅកាចទឹងអ្នកជាវិញ ពុំមានកូនក្តី មានកូនប៉ុន្មានៗក្តី លែងគ្នាវិញនោះ ឲ្យចៅពញាជាខុនក្នាក់ង៉ារយកខ្វាត់ . . . អំពីអាប្រុសខ្ញុំគេនោះហោង មេស្រីអ្នកជាតម្លឹង ៣ ដើងកោះស៊ឹង ១០ ខ្ញុំគេបាទ ៥ និមួយគួហោង លាងខ្នាសបាទ ៦ ។

មាត្រា ១ (សោត) ទោះខ្ញុំគេបក្នាត់បន្សាបោរ[១] ដ្បិតពុំបានប្រាប់ក្នាក់ង៉ារស្រុក ឲ្យចៅពញាខុនក្នាក់ង៉ារនោះ (ត្រូវ) ពិន័យជាប្រាក់ដីង ៣ តម្លឹង ១៧ ឲ្យហូតខ្វាត់ព្រះយាំងពុះគ្រឹងហោង ។

---

១ ប្រហែលជាសំដៅសេចក្តីថា លាក់បំពួនបំបាំងចោរទេដឹង ។

## បក្សីធំៗ

# រឿងព្រេងប្រទេសរូម៉ានី

លោក ម៉េង-ផើរ សាស្ត្រាចារ្យ នៅអនុវិទ្យាល័យនារី ក្រុងភ្នំពេញ
ប្រែពីភាសាបារាំង

(តមក)

---

នៅវេលាព្រឹកមួយ មេឃស្រឡះគ្មានពពកបិទបាំងព្រះអាទិត្យ, នាងក្រមុំជាអ្នកបោសព្រះរាជឈានចូលមកបង្គំគាល់ព្រះរាជា ហើយក្រាបទូលថា: បពិត្រព្រះសម្មតិទេពមហារាជ! ប្រជារាស្ត្រទាំងអស់មានសេចក្ដីសប្បាយក្រៃពេក ព្រោះបក្សីទាំងនេះនិយាយហើយ; គ្រាន់តែអ្នកគង្វាលចៀមម្នាក់ដើរចូលមកក្នុងព្រះវិហារ សាប់តែបក្សីតាំងចំគាងរងាវពេញទំហឹង ស្ទើរតែបែកបំពង់ក; គឺជាលើកទីពីរហើយ សូមព្រះករុណាថ្ងៃវិសេសទ្រង់ជ្រាប កាលណាអ្នកគង្វាលចៀមចូលមកក៏រងាវ, ហើយក៏ឈប់រងាវក្នុងវេលាដែលអ្នកគង្វាលនោះដើរចេញទៅវិញ ។

ព្រះរាជាមានព្រះបន្ទូលថា: ចូរឲ្យគេនាំអ្នកគង្វាលចៀមមករកយើងយ៉ាងប្រញាប់ ។

នាងនោះក្រាបបង្គំទូលស្នងថា: បពិត្រព្រះសម្មតិទេព! អ្នកគង្វាលចៀមនោះ ជាអ្នកបរទេស មនុស្សក្នុងទីនេះគ្មាននរណាស្គាល់ទេ, ខ្ញុំ

ម្ចាស់ឮគេនិយាយថា ព្រះរាជបុត្រារបស់ព្រះអង្គបាត់ឲ្យក្រុមល្បាតស៊ើប រកដើម្បីចាប់អ្នកនោះ ។

ព្រះរាជាមានព្រះតម្រាស់ថា: ត្រូវមីហនឯងស្ងៀម កុំនិយាយ បង្ខូចកូនរបស់អញ; ហេតុយ៉ាងដូចម្តេច បានជាមីហនឯងហ៊ានចោទ ប្រកាន់កូនប្រុសទាំងពីររបស់អញ? ។

ប៉ុន្តែព្រះរាជាបានបាត់ការយ៉ាងស្ងាត់ឲ្យក្រុមនគរបាល ឃ្លាំចាំ មើលអ្នកគង្វាលចៀម កាលណាក្រុមនគរបាលបានឃើញវាចូលមក ក្នុងព្រះវិហារ ត្រូវចាប់យកមកថ្វាយព្រះអង្គ ។ រឿងនេះតើប្រព្រឹត្តទៅ ដូចម្តេចទៀត? គឺនៅថ្ងៃបុណ្យទី ១ ព្រះរាជាក៏យាងទៅកាន់ព្រះវិហារដែរ ដើម្បីទទួលព្រះសណ្តាប់នូវសំនៀងនៃបក្សីដោយព្រះកាណ៌ទទួលផង ដើម្បី ទតអ្នកគង្វាលចៀមដ៏អស្ចារ្យដោយព្រះនេត្ររបស់ព្រះអង្គផង ។ ជា គ្រោះល្អ បើកុំតែព្រះរាជាយាងទៅ ការតយុទ្ធរវាងក្រុមមនុស្សស្មាត់ របស់ព្រះអង្គនិងក្រុមមនុស្សរបស់ព្រះរាជបុត្រ ក្នុងការដណ្តើមចាប់នូវ អ្នកគង្វាលចៀមតែរៀងខ្លួន មិនដឹងជាយ៉ាងដូចម្តេចទៅទេ ។ ព្រះរាជា បង្គាប់ឲ្យគេនាំអ្នកគង្វាលចៀមទៅក្នុងវាំង ហើយប្រាប់កុំឲ្យនរណាធ្វើទុក្ខ បុកម្នេញអ្វីឡើយ ព្រោះព្រះរាជាហាក់ដូចជាមានព្រះហឫទ័យទន់ទោរ ទៅរកអ្នកគង្វាលចៀមនោះដែលនៅក្មេងនៅឡើយ ហើយមានទំនងជា អ្នកសុភាពនិងមានអាការជាអ្នកក្លាហានផង ។

លុះចេញផុតពីព្រះវិហារហើយ ព្រះរាជាទ្រង់រំភើបក្នុងព្រះហឫទ័យពន់ពេក ក៏ស្ដេចតម្រង់ទៅព្រះបរមរាជវាំងតែម្ដង ។

ព្រះរាជាត្រាស់សួរអ្នកគង្វាលចៀមថា: ម្នាលកុមារ! ចូរឯងនិយាយរឿងប្រាប់យើងមើល: តើឯងមកពីណា? ឯងមានឪពុកម្ដាយឬទេ? ហេតុដូចម្ដេចបានជាឯងមកក្នុងទីនេះ? ។

– បពិត្រព្រះមហារាជដ៏ទ្រង់នូវមហានុភាព! រឿងរបស់ទូលព្រះបង្គំវែងណាស់. ខ្ញុំទូលព្រះបង្គំមានទាំងឪពុកម្ដាយទាំងបងប្រុស; បើព្រះអង្គសព្វព្រះរាជហឫទ័យឲ្យទូលព្រះបង្គំរ៉ាយរ៉ាប់ អំពីទូលព្រះបង្គំមកពីទីណា នឹងហេតុដូចម្ដេចបានជាមកក្នុងទីនេះ នោះត្រូវមានពេលវែងទើបនិយាយថ្វាយបាន; បើដូច្នេះ ទូលព្រះបង្គំនឹងត្រឡប់មកថ្លែងរឿងនេះថ្វាយ នៅវេលាព្រឹកស្អែកពីព្រលឹម ព្រោះឥឡូវនេះហួសពេលហើយ ។

– ម្នាលកុមារ! ចូរចាំណា៎! ស្អែកនៅពេលថ្ងៃរះ យើងរង់ចាំឯង ។

ស្អែកព្រលឹមឡើង អ្នកគង្វាលចៀមមកតាមព្រះរាជបណ្ដាំ ហើយមិនយូរប៉ុន្មាន គេក៏នាំទៅថ្វាយព្រះរាជា ។

ព្រះរាជាមានព្រះបន្ទូលសួរថា: ម្នាលកុមារ! ចូរឯងនិយាយមើល: តើហេតុដូចម្ដេច ក៏បក្សីទិព្វរោទ៍ក្នុងកាលដែលឯងចូលមកក្នុងព្រះវិហារ ហើយឈប់រោទ៍ក្នុងវេលាដែលឯងចេញទៅវិញ? ។

— បពិត្រព្រះមហាកដ៏ទ្រង់នូវអំណាច! ព្រះអង្គនឹងជ្រាបរឿងនេះព្រមទាំងរឿងដទៃទាំងឡាយដោយជាក់ច្បាស់ លុះតែទ្រង់បណ្ដោយឲ្យទូលព្រះបង្គំនិយាយប្រាប់នូវរឿងសព្វគ្រប់ កុំបីព្រះអង្គបង្អាក់ឡើយ ។

ទូលព្រះបង្គំ ឪពុកក៏មាន បងប្រុសក៏មាន, ទូលព្រះបង្គំបានចេញពីផ្ទះលោកឪពុក មានបំណងនឹងស្វែងរកនូវឥដ្ឋារម្មណ៍ គឺអារម្មណ៍ដែលលោកឪពុកត្រូវការពន់ពេក តែលោកមិនអាចនឹងធ្វើឲ្យសម្រេចបានតាមសេចក្ដីបំណង; លុះត្រាចទៅបានពីរ – បីថ្ងៃ ទូលព្រះបង្គំបានដល់មាត់ព្រៃមួយដ៏ស្អាតត្រជាក់ដែលមានផ្លូវបែកជាច្រើន, ទូលព្រះបង្គំកំណត់ទុកក្នុងចិត្តថានឹងសម្រាកកាយមួយគ្រាក្នុងព្រៃនោះ ហើយក៏តាំងបង្កាត់ភ្លើងយកស្បៀងចេញមក ប្រុងប្រៀបនឹងបរិភោគ ស្រាប់តែលេចកញ្ជ្រោងកញ្ចាស់ពីណាមួយ មកមួយរំពេច នៅក្បែរទូលព្រះបង្គំ ៗមិនដឹងជាវាមកពីខាងទិសណា ទូលព្រះបង្គំក៏មិនបានឃើញ, បើតាមស្មានប្រហែលជាវាចេញពីក្នុងដីមក ។

កញ្ជ្រោងនិយាយនឹងទូលព្រះបង្គំថា: ខ្ញុំសូមអង្វរចិត្តអ្នក, អ្នកមេត្តាឲ្យខ្ញុំអាំងភ្លើងផង ខ្ញុំរងាញាក់គ្រុន ចូរអ្នកមើល ធ្មេញរបស់ខ្ញុំរណ្ដំគ្នាកិកៗ, ម្យ៉ាងទៀតសូមៈមេត្តាករុណាឲ្យនំបុ័ងមួយដុំនឹងស្រាមួយកែវដល់ខ្ញុំផង ដើម្បីនឹងបង្អន់ការស្រេកឃ្លាន ដែលកបាក់ដោតខ្លួនខ្ញុំ, ហើយបើចង់ឲ្យ

ខ្ញុំអាចអាស្រ័យជាសុខនឹងអាំងភ្លើងឥតភ័យ សូមអ្នកចងដៃទុកឲ្យជាប់ខ្ជាប់ក្រែងរាខ្ញុំ ។

ទូលព្រះបង្គំឆ្លើយថា: មិនអីទេ ចូរឯងមកអាំងភ្លើងចុះ, នេះនែះស្បៀងអាហារអញ ដបស្រាអញ ចូរឯងអាស្រ័យនឹងអាំងតាមគាប់ចិត្តចុះ ។

រួចទូលព្រះបង្គំចងដៃជាប់ ហើយយើងទាំងពីរនាក់ គឺ ទូលព្រះបង្គំនឹងករញ្ញាងដដែកគ្នាលេងពីនេះពីនោះ, និយាយទៅ និយាយមក ទូលព្រះបង្គំថ្លែងប្រាប់វា នូវការណ៍ដែលទូលព្រះបង្គំត្រូវស្វែងរក ហើយសួរវាក្រែងលោកដឹង តើទូលព្រះបង្គំនឹងត្រូវធ្វើដូចម្តេច បែបណា ដើម្បីញុំាងកិច្ចនុះឲ្យបានសម្រេចដូចក្តីប្រាថ្នា ។

ករញ្ញាងឆ្លើយប្រាប់ថា: រឿងនេះ សូមលោកកុំព្រួយឲ្យសោះ, ស្អែកឡើង ពេលសងកើត យើងនឹងចេញធ្វើដំណើរទាំងពីរនាក់ ហើយខ្ញុំអាចធានាអះអាង បើការណ៍ហ្នឹងមិនសម្រេច ខ្ញុំឲ្យអ្នកចងកខ្ញុំព្យួរឡើង ។

យើងនៅអាំងភ្លើងទាំងពីរនាក់ យើងបបួលគ្នាបរិភោគអាហារជាកល្យាណមិត្ត រួចករញ្ញាងឲ្យពរដល់ទូលព្រះបង្គំថា: រាត្រីសួស្តី ! ហើយវាក៏អន្តរធានមួយរំពេចបាត់ទៅ ដូចជាខ្មោចលង, ទូលព្រះបង្គំចេះតែគប់ប្រមល់ក្នុងចិត្ត មិនដឹងធ្វើដូចម្តេចនឹងឲ្យដឹងថាវាមកពីទិសណា រួចវាចេញទៅវិញតាមកន្លែងណា, កំពុងតែគិតចុះគិតឡើង ស្រាប់តែទូលព្រះបង្គំទទួលព្រះរាជទានដំណេកលក់ទៅ ។

លុះព្រឹកឡើង កញ្ជ្រោងមកដល់ ទូលព្រះបង្គំកំពុងតែសំឡឹងមើលដុំថ្មនេះដែលមានរាងដូចជាមនុស្សពីរនាក់ ដូចជារូបសេះពីរ ដូចជារូបឆ្កែពីរ, កាលកញ្ជ្រោងមកដល់ហើយ ទូលព្រះបង្គំក៏រៀបប្រដាប់ប្រដានឹងធ្វើដំណើរចេញទៅ ។

សត្វកញ្ជ្រោងលោតដំឡើងបីដង ស្រាប់តែក្លាយខ្លួនជាមនុស្សម្នាក់ស្ញើចញញឹមនៅពីមុខទូលព្រះបង្គំ, គាត់និយាយបណ្ដើរ ដើរបណ្ដើរប្រាប់ទូលព្រះបង្គំថា: កន្លែងដែលទូលព្រះបង្គំអាស្រ័យដំណេកយប់មិញ គឺជាដីរបស់គាត់ៗ មានប្រពន្ធកូន ប៉ុន្តែគាត់ត្រូវសិល្បរបស់គេ ១ ដាក់ទណ្ឌកម្មឲ្យគាត់ទទួលស្បែកកញ្ជ្រោងលុះត្រាតែមាននរណាចិត្តល្អបានមកប្រទះ ហើយគាណិតឲ្យអាំងភ្លើង ឲ្យនំបុ័ងស៊ី ឲ្យស្រាផឹក ទើបឲ្យរបូតចេញពីស្បែកកញ្ជ្រោង; ឥឡូវគាត់បានរួចពីគ្រោះថ្នាក់ វាសនាអាក្រក់ហើយ ហេតុនេះ គាត់នឹងតាមជូនទូលព្រះបង្គំទៅសព្វទិសទីកន្លែង ហើយនឹងមិនលះបង់ទូលព្រះបង្គំឡើយ មុនដែលទូលព្រះបង្គំមិនទាន់សម្រេចកិច្ចការស្វែងរកវត្ថុដែលត្រូវការ ។

ទូលព្រះបង្គំដឹងដូច្នោះហើយ មានសេចក្ដីរីករាយក្រៃពេក ហើយយើងនាំគ្នាដើរទៅ ចេញវាលចូលព្រៃ ចេញព្រៃចូលវាល ក៏បានដល់មាត់ព្រៃមួយ រួចនាំគ្នាដេកក្នុងទីនោះ ។ សំឡាញ់របស់ទូលព្រះ

បន្តិប្រាប់ថា: ថៃស្អែក យើងត្រូវចូលក្នុងដែនយក្ស គឺជាប្រទេសដែលមានវត្ថុដែលទូលព្រះបង្គំត្រូវការរក ។

ស្អែកឡើង យើងចូលក្នុងនគរយក្ស ដើរដោយសេចក្ដីប្រយ័ត្ន លុះវេលាល្ងាច យើងបានដល់ទីប្រាសាទរបស់វា ។ គេមិនអាចពណ៌នានូវលំអដែលមាននៅក្នុងទីនោះឡើយ គឺសួនច្បារ ប្រកបដោយផ្កាគ្រប់ពណ៌និងដើមឈើគ្រប់បែប, ដំបូលប្រាសាទក្ដីតាំងដូចជាកញ្ចក់ត្រចៀក, កំពែងមានគាក់តែងដោយរូបផ្សេង ៗ ដោយផ្កាចម្លាក់ក៏មាន ដោយក្បាច់ដើងកោសទឹបមាសខាងក្នុង មានទឹកបាញ់ហូរឡើងទៅលើដូចកាំជ្រួច ។ ដូនជាមានក៏ពួដែរពេលនោះ ពួកយក្សមិននៅ យើងឃើញស្រីក្រមុំម្នាក់ យ៉ាងស្អាតចេញមកទទួលយើងនៅមាត់ទ្វារចូល ។

នាងក្រមុំនោះប្រាប់យើងថា: វេលាដែលយក្សមិននៅ អ្នកមិនត្រូវចូលមកក្នុងទីនេះទេ សេចក្ដីទុក្ខនឹងមានដល់អ្នកជាមិនខាន ។

ហើយនាងសែនត្រេកអរ ដោយបានជួបមនុស្សដូចគ្នា មកពីត្រើយសមុទ្រខាងនាយ ព្រោះនាងនុះ គឺយក្សចាប់យកមក ។

លុះយើងបានប្រាប់វត្ថុបំណងដល់នាង ៗ ក៏ប្រាប់ថា: វត្ថុដែលយើងត្រូវស្វែង មិនមែននៅក្នុងទីនេះទេ គឺមាននៅក្នុងនគរយក្សមួយផ្សេងទៀត ដែលជាញាតិនឹងយក្សនេះ ។

នាងក្រមុំប្រាប់ខ្ញុំថា: ចូរអ្នកអញ្ជើញទៅចុះ ប្រហែលនឹងបានសម្រេច ដោយប្រសិទ្ធពរព្រះជាម្ចាស់ជួយផង, ហើយលុះអ្នកត្រឡប់មកវិញ ចូរនាំខ្ញុំទៅផងកុំខាន ។

រួចនាងក្រមុំឱ្យខ្ញុំម្ចាស់ស្បថដាក់ក្បាលអាពុកទូលព្រះបង្គំជាប្រធាន ថាមិនត្រូវលះបោលនាងក្នុងនគរយក្ស គឺត្រូវតែជួយនាំនាងត្រឡប់មកកាន់ផែនដីយើងវិញ; រួចយើងនាំគ្នាចេញទៅ, បើតាមពិត នាងក្រមុំពេញចិត្តនឹងទូលព្រះបង្គំណាស់ ។

លុះទៅដល់ យើងឈប់សំរាកមួយយប់នៅខាងមុខនគរយក្ស, វេលាស្អែក ពេលថ្ងៃរះយើងចូលក្នុងនគរយក្ស ។ ថ្ងៃត្រង់យើងបានដល់កំពែងរបស់វា ដែលមានសភាពល្អស្អាតលើសកំពែងមុនទៅទៀត ។ យើងចុះពីសេះ ហើយសំឡាញ់របស់ទូលព្រះបង្គំ ត្រូវត្រឡប់មកវិញតាមដំបូន្មាននៃនាងក្រមុំ, ចំណែកទូលព្រះបង្គំបេះតែដើរតម្រង់ទៅកាន់ក្រោលសេះរបស់យក្ស ។

មានសេះយ៉ាងច្រើន ដេកសម្រាកនៅទីនោះ ។ សេះមួយងាកមើលទូលព្រះបង្គំ ។ ស្ទាបក្អែកវា ទាញស៊កត្រចៀកវា ដេញវាឱ្យក្រោកឈរឡើង បន្ទាំបង្ហៀរ រួចលោតផែលទំលើខ្នង ហើយទូលព្រះបង្គំជិះបរបំបាយទៅបណ្ដាប់យកទ្រូងសត្វបក្សីទិព្វ ដែលព្យួរនៅត្រង់សំយាបប្រាសាទ ។ (មានត)

# សព្ទបារាំងប្រែជាខ្មែរ

របស់

គណៈកម្មការវប្បធម៌

## ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម រួបរួម

(តមក)

---

Phénomène = ធាតុភូត, ការប្រាកដ

Dieu = អាទិទេព

Hypothèse = សម្មតិកម្ម, ការស្មាន

Destin = ជោគវាសនា

(1er – 7 – 49)

Empereur = អធិរាជ

Impératrice = អធិរាជិនី

Dialecte = គ្រាមភាសា

Langue diplomatique ភាសាទូត

Diplômate = អ្នកការទូត

Amlassadeur = ឯកអគ្គរាជទូត

Consul Général = កុងស៊ុលធំ

Diplômatie = ការទូត

Légation = ស្ថានអគ្គរាជទូត

Vice-Consul = កុងស៊ុលរង

Consulat = ស្ថានកុងស៊ុល

(5 – 7 – 49)

Jury d'examen = គណៈមេប្រយោគ

(8 – 7 49)

Armement សព្វាវុធ

Equipement = យោធបរិក្ខារ

Division blindée = កងពលក្រោះ

Aile volante = ស្លាបហោះ

Matériel roulant = សម្ភារយាន

Mobilisation = ការកេណ្ឌ

Officier d'Etat-Major = នាយទាហានសេនាធិការ.

Munitions = គ្រាប់រំសេវ

Revue des troupes = ពិធីត្រួតពល

Inspection des troupes = ការពិនិត្យកងពល

(16 – 7 – 49)

Office de riz = មន្ទីរស្រូវ

Institut Océanographique = វិជ្ជាស្ថានមហាសាគរលេខ

Champion = អ្នកជើងឯក

Complémentaire = បំពេញ

Supplémentaire = បន្ថែម

(26 — 7 — 49)

Initialler = ចុះអក្សរអាទិសង្កេត

Parapher = ចុះហត្ថលេខាសង្ខេប

Lettre d'initiative = អក្សរអាទិស័ង្កេត

Initiative = ដើមគំនិត

Rédaction = ការតែងសេចក្តី

Rédacteur = អ្នកតែងសេចក្តី

Sujet (de rédaction) = រឿង (នៃការតែងសេចក្តី)

Opération (du problème = ការធ្វើលេខ (ចំណោទ)

Système métrique = របៀបមាត្រាម៉ែត្រ

Cœfficient = មេគុណ

Notre éliminatoire = ពិន្ទុត្រូវធ្លាក់

Solution (problème) = ការដោះ (ចំណោទ)

(29 — 7 — 49)

Avertissement (peine disciplinaire)= ការដាស់តឿន, ការព្រមាន

Déterminer = កំណត់, សម្រេច, បញ្ជាក់

Définition = អត្ថន័យ

(2 – 8 – 49)

Poste et télécommunication = ប្រៃសនីយ៍និងទូរគមនាគមន៍

Confort = ផាសុកភាព

Inconfort = អផាសុកភាព (អផ្សុក)

Confortable = ផាសុក

Utile = មានប្រយោជន៍

Utilité = ប្រយោជន៍

Nécessaire = ចាំបាច់

Nécessité = ការចាំបាច់, ការខានពុំបាន

Indispensable = ដែលខានពុំបាន

Effet = ផល

En effet = យ៉ាងហ្នឹងហើយ, ដូច្នោះមែន, ព្រោះហេតុនោះ

Réalité = របស់ពិត, ការពិត

Réaliste = អ្នកប្រាកដនិយម

Réel = ពិត, ប្រាកដ

(មានត)

## រឿងព្រេងភូមា

# លោក សាង - សារ៉ាត លេខានុការក្រសួងហិរញ្ញវត្ថុ

*ប្រែពីភាសាបារាំងមកជាខ្មែរ*

(តមក)

## ៦ — ស្រីចិត្តមិនត្រង់នឹងប្តី

"ការក្បត់ចិត្តប្តី ជាមន្ទិលស្រី ក្នុងលោកទាំងពីរ លោកនេះរងទុក្ខ អាប់មុខហ្មងកេរ្តិ៍ លោកមុខធ្លាក់ទៅ ក្នុងអវិចី" ។

ក្នុងសាសនាព្រះពុទ្ធ ថេមិយ៍ៈ «Thermaydax ទី ១៦, ព្រះពុទ្ធអង្គនេះ ដូចអ្នកផងជ្រាបស្រាប់ហើយ ព្រះអង្គមានព្រះជន្មចំនួន ៩០.០០០ ព្រះវស្សា ។ កាលនោះ នៅកោះសីឡង់ (Ceylan) មានបុរសម្នាក់ជាកូនមហាសេដ្ឋី កាលវ័យចំរើនធំឡើង ក៏ចាប់ចិត្តស្រឡាញ់រូបនារីម្នាក់ ដែលត្រូវជាកូនមហាសេដ្ឋីមួយទៀត នៅក្នុងភូមិនោះដែរ ។ ឯមាតាបិតាទាំងសងខាងបានស្រុះស្រួលគ្នា ហើយរៀបមង្គលការបុត្រាបុត្រីទាំងពីរប្រាណយ៉ាងអឹកធឹក ។

លុះដល់រៀបការរួច បុរសជាស្វាមីត្រឡប់ជាមិនសប្បាយចិត្តដូចប្រាថ្នាសោះ ទើបនិយាយនឹងភរិយាថា "អូនសំឡាញ់ ! ឪពុកម្តាយរបស់បងនឹងឪពុកម្តាយរបស់អូន ជាអ្នកមានធនធានសំបើមណាស់

ប៉ុន្តែយើងទាំងពីរនេះ គ្មានរបស់អ្វីដែលជារបស់យើងទេ ; ហេតុដូច្នេះ បងគិតសូមលាអូនមួយគ្រាសិន ទឹងជិះកប៉ាល់ទៅស្រុកក្លុកទឹង ស្រុកពេជ្រ ដើម្បីរកធនធានតាមកំឡាំងរបស់បង " ។

នាងជាកិរិយាលុះឮដូច្នោះ ក៏ព្រួយចិត្តជាខ្លាំង និយាយទៅកាន់ស្វាមីវិញថា " ឱគូជីវិតរបស់អូន ! មានតែពួកអ្នកក្រដែលរស់នៅម្នាក់ឯងវេទនាជាទិច្ច គ្មានជាប់ចំណងអ្វីនៅនាលោកនេះទេ ទើបគេទៅតាមមហាសមុទ្រឆ្លងកាត់ព្យុះខ្យល់ទឹងគ្រោះថ្នាក់ផ្សេង ៗ ដើម្បីស្វែងរកធនធាន ; ឯរូបអ្នកបងវិញឆ្ងាយអំពីហានៈ នោះជាអនេក តែឯអ្នកបងគិតថា: " បើអូនឃ្លាតអំពីបងទៅ អូនគ្មានបង្អែកឯណាទៀតទេ, ដូច្នេះសូមបងគិតទៀតថា: អូនស្រឡាញ់បងណាស់, ឪពុកម្ដាយរបស់យើងជាអ្នកមានទ្រព្យសម្បត្តិច្រើន, លោកក៏គង់ចែកទ្រព្យសម្បត្តិរបស់លោកមកឲ្យយើងខ្លះដែរ ទោះបីលោកនៅរស់ក្តី លោកមិនធ្មេចក្អកទេ ព្រោះលោកស្រឡាញ់យើងណាស់ " ។

– ពិតមែនហើយអូន, ប៉ុន្តែយើងត្រូវតែមានទ្រព្យណាមិនមែនជាទ្រព្យកើតឡើងអំពីសេចក្តីជ្រះថ្លាសទ្ធារបស់លោក, យើងត្រូវតែមានទ្រព្យណាដែលកើតឡើងអំពីកិច្ចការរបស់យើងផ្ទាល់, បើសិនណាបងស្លាប់កណ្តាលផ្លូវ ឈ្មោះថា បងស្លាប់ដោយកិត្តិយស រួចគេនឹងគោរពដល់បងមិនខាន; មនុស្សណាដែលមិនចេះរកចិញ្ចឹមជីវិតខ្លួនឯង មនុស្ស

នោះជាសត្វធុនអន់ជាបំផុត, ដូនកាលគេមើលងាយផង; មួយទៀត យើងមិនត្រូវរស់នៅដោយគ្រាន់តែស៊ីផឹកដេកដោយឥតកម្រើកម្រាមដៃ តាំង ១០ នោះទេ, អ្នកប្រាជ្ញបានបារគុងសៀវភៅធម៌ថា "ជនណាមិនខ្វាចស្លាប់ដើរតាមសមុទ្ររលកគគ្រឹកគគ្រេងដើម្បីស្វែងរកទ្រព្យសម្បត្តិ ជននោះទើបសមជាមនុស្សគួរឲ្យគេកល់គ្នាសរសើរបាន តោះបើមិនបានទ្រព្យនោះដូចបំណងក៏ដោយ; ហេតុដូច្នេះ កុំឲ្យអូនគិតជវែលៗឲ្យសោះ ព្រោះបងប្រាកដជាទៅហើយ" ។

លុះកាលណាបុរសបានឧបថ្ថាក់ថ្មកកិរិយាដោយស្នេហាយ៉ាងស្និទ្ធស្នាលហើយ ក៏ចេញដំណើរទៅ ដូចពាក្យដែលបានពោលមែន ។

ដល់យូរបន្តិចមក នាងកិរិយានៅម្នាក់ឯងកើតទុក្ខព្រួយក្រៀមក្រំជាខ្លាំង; ប៉ុន្តែធម្មតាស្រីដែលក្រាស់ដោយតណ្ហាតែងមិនស្កប់នឹងប្តីរបស់ខ្លួនទេ ។ ឯនាងនេះក៏ជាស្រីតណ្ហាក្រាស់ផង មានវ័យនៅក្មេងផង នាងឆាប់ភ្លេចប្តី នាងបានទៅមកធ្វើអន្តករជាមួយបុរសអ្នកបំរើរបស់ឪពុកម្តាយនាងម្នាក់ឈ្មោះប៉ាយតា (Payta) ។ ប៉ាយតានេះមានវ័យនៅក្មេង មានរូបល្អ អាយុប្រមាណស្មើនឹងអាយុនាង ។

ថ្ងៃមួយ ប្រសសង្សារនាង បាននិយាយនឹងនាងថា "អូន! យើងរស់នៅជាមួយគ្នាបានសុខសប្បាយណាស់; ប៉ុន្តែបើសិនណាប្តីដើមរបស់អូនមកវិញ តើយើងគិតយ៉ាងណា? យើងគិតបែកគ្នាឬអ្វី? ។ នាងគេ

គិតក្នុងចិត្តជាយូរបន្តិច ទើបយុវនារីស្រាយបញ្ហានេះ ដែលមើលទៅហាក់គ្មានផ្លូវដោះ រួចនាងនឹងបុរសម្នាក់និយាយថា: "ឱបង! ប្អូននឹកឃើញហើយ យប់នេះបងទៅឯព្រៃខ្មោច ហើយបងយករូបខ្មោចស្រីម្នាក់ដែលគេទើបកប់យកមកឲ្យខ្ញុំ, យើងយកខ្មោចនេះទៅដាក់លើដំបូលផ្ទះ ហើយយើងដុតផ្ទះរបស់យើងទៅ; លុះកាលណាឪពុកម្ដាយរបស់ខ្ញុំឃើញរូបខ្មោចដែលឆេះកេលខ្មោះនោះ លោកទាំងនឹកស្មានថា: ខ្ញុំស្លាប់ក្នុងអគ្គិភ័យនេះ ផុតប្រុះមិនខាន, រួចយើងនាំគ្នាទៅនៅកន្លែងមួយទៀតដែលគ្មានអ្នកណាមកជំទាស់ដល់សេចក្ដីស្នេហារបស់យើង" ។

ប៉ាយតាយល់ឃើញត្រូវផង ក៏ធ្វើតាមបង្គាប់របស់នាង ។ ក្នុងវេលាដែលភ្លើងកំពុងឆេះខ្លាំង ប៉ាយតាទៅជាមួយស្រីសង្សារតាមផ្លូវបតបែនលុះត្រាតែដល់ភូមិមួយដែលនៅឆ្ងាយដាច់ស្រយាលពីស្រុកកំណើតនាង ។

ឯឪពុកម្ដាយរបស់នាង បានទឹកស្មានថា: កូនស្រីរបស់ខ្លួនស្លាប់ក្នុងភ្លើង ក៏យំសោកថោកប្រាណ ហើយបានធ្វើបុណ្យបញ្ជូនឲ្យនាងយ៉ាងបរិបូណ៌ យកខ្មោចនោះទៅដុតនឹងឈើខ្លឹមច័ន្ទន៍ក្រយ៉ៅឈ្មោះគង់ យ៉ាងគគ្រឹកគគ្រេង ។

សុភាសិតថា "សេចក្ដីស្នេហានាំឲ្យមនុស្សទៅជាខ្វាក់មិនចេះគិតវែងឆ្ងាយ" ។ ហេតុនោះ បានជាប៉ាយតានឹងនាងស្រឡាញ់គ្នាណាស់ គ្មានខ្លាចអ្វី គ្មានខ្លាចអ្នកណាបន្ទោស គ្មានទឹកគិតភ័យអ្វីឡើយ ។

ក្នុងពេលដែលរត់ទៅនោះ ជនទាំងពីរនាក់មានសេចក្ដីធ្វេសប្រហែស ឥតបានយកអ្វីជាប់ជាមួយទៅផងទេ មានតែមាសពេជ្របន្តិចបន្តួច, ដល់យូរបន្តិចទៅ ក៏ចាយវាយអស់គ្មានសល់អ្វីសោះ ។

សេចក្ដីពិត កាលណាសេចក្ដីស្រេកឃ្លានគាបគ្រពះ សេចក្ដីស្នេហាយ៉ាងខ្លាំងក្រឡប់ជាអន់ថយវិញ ។ នេះជាពាក្យចាស់ទុំជាន់មុនណា ។ ហេតុតែជនទាំងពីរនាក់ធ្លាក់ក្នុងស្ថានសុភាសិតនេះហើយ បានជាក្នុងថ្ងៃមួយ ស្វាមីភរិយា ឱបក្រសោបគ្នារួចហើយ, ស្រីសង្សារនិយាយថា: "បង ! ប្អូនឃើញថាបងស្រឡាញ់ប្អូនខ្លាំងណាស់ ឯប្អូនក៏ស្រឡាញ់បងណាស់ដែរ, ប៉ុន្តែឥឡូវនេះ យើងក្រលំបាកខ្លាំង, ហេតុដូច្នេះ យើងមុខជានឹងស្លាប់ដោយអត់ឃ្លានកណ្ដាលតណ្ហារបស់យើងពុំខាន ; ប្អូនសុំចិត្តបងចុះ, យើងត្រូវនាំគ្នាទៅផ្ទះរបស់ឪពុកម្ដាយប្អូនវិញ, គាត់ចំណាំបងមិនបានទេ ប្រហែលគាត់ភ្លេចមុខបងហើយ ដោយគាត់មិនបានចាប់គិតនឹកនាដល់រូបបង ; ចំណែកខាងប្អូនវិញគាត់មុខជាស្មានថា រូបប្អូននេះគ្រាន់តែដូចរូបកូនរបស់គាត់, ប្អូនហាក់ថា មុខជាគាត់ឲ្យលុយកាក់ប្រាក់កាសមកប្អូននឹងបងសម្រាប់ទិញម្ហូបអាហារនឹងសំលៀកបំពាក់ផ្សេង ៗ, បើនិយាយសរុបទៅ គឺថាគាត់មុខជាឲ្យរបស់ដែលយើងត្រូវការទាំងប៉ុន្មានមិនខាន ។

ប៉ាយតាដែលមានបំណងស្រេចគ្នានឹងភរិយាដែរ ក៏ព្រមធ្វើតាមនាង ។ លុះកាលណាបរិភោគអាហារស្រស់ស្រួបពេលព្រឹកបន្តិចបន្តួចរួចហើយ ប្តីប្រពន្ធទាំងពីរនាក់នាំគ្នាត្រឡប់មកផ្ទះរបស់ឪពុកម្តាយវិញ ; ដល់ពេលល្ងាច ក៏បានមកដល់មាត់ទ្វារសួនច្បារដែលលាតសន្ធឹងពីមុខគេហដ្ឋាន ហើយបាននាំគ្នាអង្គុយសំរាកនៅក្រោមម្លប់ដើមឈើមួយធំដែលមានផ្កាកែវពោរពាស ហើយដែលបក់ក្លិនក្រអូបឈ្ងុយឈ្ងប់ដូចផ្កាក្រូច ។

ក្នុងពេលនោះ ពួកខ្ញុំបំរើដែលធ្លាប់តែចុះពីលើផ្ទះតាមធម្មតា ដើម្បីយកទឹកទៅជ្រួចសែនខ្មោចនាងដែលស្លាប់ក្នុងអគ្គីនោះ បានឃើញស្វាមីភរិយាទាំងគូនៅអង្គុយលើស្មៅ ក៏ឈប់ឈរសំឡឹងមើល ហើយនិយាយគ្នាថា : "ឃើអើបើសិនណាជានាងនេះគ្មានប្តី គេទៀងតែថាចៅ-ហ្វាយស្រីរបស់យើងពុំខាន" ។ រួចអ្នកបំរើទាំងនោះយកដើងពានមាសត្រឡប់ទៅវិញ ដោយគតបានសែនព្រេនអ្វីទេ ហើយនិយាយរ៉ាយរ៉ាប់ប្រាប់អ្នកស្រីដែលជាម្តាយរបស់នាងគ្រប់ប្រការ ។

ឯអ្នកស្រីនេះក៏ប្រុះអំពីផ្ទះយ៉ាងប្រញាប់ ដើរទៅក្នុងសួនច្បារតម្រង់ទៅគល់ឈើធំ ដែលអ្នកទាំងពីរអង្គុយនៅ ក៏បានឃើញកូនស្រីរបស់គាត់ ៗ គាត់ស្រក់ទឹកភ្នែកនៅស្ងៀមមួយកន្ទុង ឈរមើលកាំងស្មារតី ប៉ុន្តែឥតហ៊ាននិយាយនឹងកូននាងទេ ។ ក្រោយមក ដោយសារចិត្ត

ខ្លួនខ្ញាញ់ខ្លាំងពេក គាត់សង្រួបចិត្តគាត់បាន ហើយទៅអង្គុយជិតនាង សាកសួរនាងដោយមានសំឡេងយ៉ាងទន់ថា: តើនាងកូនចៅអ្នកណា? ។ កូនស្រីឆ្លើយថា: "ដំកបប្រសាសន៍អ្នកម៉ង! យើងទាំងពីរនេះជាអ្នកដំណើរ, យើងមកឈប់សម្រាកក្នុងទីនេះក្រោមម្លប់ឈើដែលមានផ្កាក្រអូបនេះបន្តិច, ឥឡូវយើងធ្វើដំណើរតទៅទៀតហើយ" ។ — ទេនាង! កុំទៅ, នាងនៅទីនេះហើយ, ខ្ញុំធានាចិញ្ចឹមនាងដូចកូនខ្ញុំបង្កើត; ព្រោះមុខរបស់នាងនាំឲ្យខ្ញុំនឹកដល់កូនស្រីសំឡាញ់របស់ខ្ញុំ ដែលអនិច្ចកម្មក្នុងក្តៅភ្លើងបាត់ទៅនោះ ហើយដែលខ្ញុំនៅតែនឹកគ្មានភ្លេចឡើយ, នាងនៅនេះចុះ ខ្ញុំសុំចិត្តនាងឲ្យអាណិតម៉ង ។

ដូចយើងដឹងស្រាប់ហើយ, ដែលនាងនេះធ្វើឲ្យម្តាយអង្គរខ្លួនយ៉ាងនេះ គឺធ្វើតែក្រៅទេ ចំណែកចិត្តឥតប្រែកែសោះ ហេតុដូច្នេះហើយទើបនាងសុខចិត្តព្រមនៅតាមអង្វរ ។ ឯអ្នកស្រីជាមាតាមានចិត្តត្រេកអរជាពន់ពេកណាស់ ហើយនាំប្តីប្រពន្ធទាំងពីរប្រាណចូលទៅក្នុងផ្ទះមួយសង់អំពីឈើម៉ៃសាក់លាបពណ៌យ៉ាងល្អឆើតឆាយ មានដំបូលច្រើនជាន់នៅក្នុងសួនច្បារនោះ ។

អស់កាលចំនួនជាច្រើនថ្ងៃខែមក ជនទាំងពីរនាក់គ្មានរឿងហេតុអ្វីទេ សឹងនៅជាសុខសប្បាយដោយសម្បូណ៌គ្រឿងបរិភោគឧបភោគគ្រប់ប្រការ ។ ឯអ្នកស្រីមិនចេះអស់ចិត្តនឹងមើលមុខនាងនោះសោះ ព្រោះ

កាលឃើញនាងជាហេតុនាំឲ្យនឹកឃើញដល់កូនស្រីសំឡាញ់របស់គាត់ ។ ប៉ុន្តែថ្ងៃមួយនោះ មានអ្នកនាំសំបុត្រមកប្រាប់ថា ប្តីដើមរបស់នាងត្រឡប់មកពីការដើរផ្សងព្រេងវិញហើយ បានទាំងនាំធនធានជាច្រើនមកផង ។ ក្នុងពេលយប់នោះ បុរសផ្សងព្រេងក៏មកដល់មែន ហើយសាកសួរគេអំពីសុខទុក្ខភរិយាខ្លួនមុនគេបង្អស់ ។ គេក៏ប្រាប់យ៉ាងច្បាស់វិញអំពីអគ្គិភ័យ និងអំពីមរណភាពយ៉ាងអស្ចារ្យ របស់ភរិយាដែលជួបប្រទះក្នុងអណ្តាតភ្លើង ឃើញតែរូបដែលត្រូវឆេះផ្សែងពេលមើលមិនស្គាល់ ព្រមទាំងប្រាប់ពីពិធីបុណ្យយ៉ាងអឹកធឹកដែលគេបានធ្វើនៅផ្នូរខ្មោចនាង ។

បុរសផ្សងព្រេងខំទប់ទឹកភ្នែកដែលហៀបនឹងហូរចេញមក ក្នុងចិត្តខ្លោចផ្សាអនេក ទើបដើរឆ្ពោះទៅកាន់ផ្ទះម្តាយដែលបានសង់ហើយចែកមួយបន្ទប់ដល់ខ្លួននោះ ។ ក្នុងពេលនោះ ខ្លួនអ្នកបានអង្គុយនៅលើកនហាល លើកន្ទេលពណ៌មួយមានស្រស់អមជុំវិញ ស្រាប់តែក្រឡេកភ្នែកទៅឃើញភរិយាខ្លួនឈរទល់ភ្នែកពីមុខ ។ ដំបូងអ្នកភាំងនៅស្ងៀម បើកភ្នែកធំដូចមនុស្សគ្មានវិញ្ញាណ រួចអ្នកនិយាយយ៉ាងខ្សឹកខ្សួលថា :

“តើហេតុអ្វីក៏ដូច្នេះ? ខ្ញុំមើលខុសឬ? ឬមួយគេកុហកអញ? អ្នកពល់គ្នាថាប្រពន្ធអញស្លាប់ ឥឡូវម្តងទៀតក៏អញឃើញនាងទាំងសាច់ទាំងឆ្អឹងយ៉ាងនេះ?” ។

(មានត)

# រឿងសាមកុក

កណ្ឌទី ៦

## អ្នកនុកញ៉ាំវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តទៅ)

---

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

*សម័យនោះ ស៊ុនគៀននឹងស៊ុនសិកជាកូនបានតែងខ្លួនជិះសេះស្រួតទៅឈរនៅមុខទាហាន, ហងចបរសេះចេញមកប្រទល់មុខហើយស្រែកដេរស៊ុនគៀនថា " អាឯងនេះ ជាពួកអាចោរស្រុកកាំងតុំងយ៉ាងកំណាច ហេតុម្តេចអាចរុករានទន្ទ្រានចូលមកដល់ដែនព្រះចៅហាន់កោតោ អាឯងមិនខ្លាចស្លាប់ទេឬ?" ហើយប្រើគៀវហោឲ្យចូលទៅតយុទ្ធ ៗ ស៊ុនគៀនប្រើហាន់តុងចេញច្បាំងនឹងគៀវហោបាន ៣០ ស្ទៀត, គាន់សេងក៏បរសេះចេញមកជួយគៀវហោទៀត, ស៊ុនសិកឃើញដូច្នោះ ក៏យិតធ្នូបាញ់ត្រូវមុខគាន់សេងធ្លាក់ពីលើសេះស្លាប់, គៀវហោឃើញគាន់*

សេនស្លាប់ដូច្នោះ ស្លុតស្លាំងតាំងស្មារតីភ័យឡើងឡង់ , ហាន់តុងក៏លើកដាវកាប់គៀវហៅធ្លាក់ពីលើសេះស្លាប់ទៅទៀត , ជៀវជាក៏បំផាយសេះត្រង់ទៅប្រឹងនឹងចាប់ហានជ ។ ភ័យណាស់ ស្ទុះដកមួកហោលពីក្បាលហើយលោតចុះពីលើសេះរត់ទៅបន្លំខ្លួនជាមួយនឹងទាហាន , ស៊ុនកៀនដេញបរទាហានចូលទៅចាក់កាប់សម្លាប់ពលហានជ តទៅដល់តំបន់ហាន់ស៊ុយ , ហានជគេចរត់រួចទៅ , ស៊ុនកៀនប្រើទាហានទៅប្រាប់អ៊ុយកាយឲ្យនាំទូកចម្បាំងឡើងទៅទទួលឯកំពង់ហាន់កាំង ។

ចំណែកហានជខូចខាតសេនាទាហានជាច្រើន ចំស្រុតរូតរត់កាត់ទៅដល់ស្រុកកេងជីវ យកសេចក្តីចូលទៅដំរាបឡៅពៀវ ។ បានដឹងភ័យណាស់ ទើបប្រឹក្សានឹងកេងលៀង ។ ឆ្លើយដំរាបថា ដែលហានជបែកមកនោះ ទាហានស៊ុនកៀនមុខជានឹងមានចិត្តកំរើប បើយើងនឹងលើកទ័ពទៅច្បាំងឥឡូវនេះ ក៏ហាក់បីដូចជាលត់ភ្លើងក្រោមខ្យល់ បើដូច្នេះយើងត្រូវតែឲ្យរក្សាបន្ទាយនឹងទ្វារស្រុកទ័ពចម្បាំងឲ្យមាំមួនសិន ហើយត្រូវឲ្យមានសំបុត្រទៅសុំកងទ័ពពីអួនសៀវលើកមកជួយ ទើបឃើញថាស៊ុនកៀននឹងមិនប្រវូសរ៉ាយបាន ។ ឈួម៉ឆ្លើយថា ដែលកេងលៀងថានោះមិនត្រូវសោះ ព្រោះទ័ពស៊ុនកៀនលើកមកដល់ដែនកំពែងហើយត្រូវតែបម្រុងរក្សាស្រុកឲ្យមាំមួនក្នុងគ្រានេះ ដែលនឹងធ្វើសំបុត្រទៅសុំកងទ័ពអួនសៀវមកជួយនោះ មុខជាមិនទាន់ការ ឥឡូវនេះខ្ញុំបានសុំយក

អាសាលើកទាហានចេញទៅវាយទ័ពស៊ិនគៀនជាមុន ។ ឡេវពៀវបានស្តាប់ហើយក៏យល់ព្រម ហើយប្រគល់ទាហានឲ្យឈួម៉ចំនួនមួយម៉ឺនលើកចេញទៅដល់ភ្នំហ៊ីសាន់ ក៏បោះកងទ័ពឈប់នៅទីនោះ ។ ឯស៊ិនគៀនមិនបានដឹងថាឈួម៉លើកទ័ពមកតាំងនៅទីនោះទេ ក៏លើកទាហានស្រុតរូតទៅដល់ភ្នំហ៊ីសាន់ពីម្ខាង , ឈួម៉ដឹងច្បាស់ក៏ឡើងសេះកាន់លំពែងចេញមកឈរមុខទាហាន, ស៊ិនគៀនឃើញឈួម៉ក៏និយាយនឹងពួកទាហានថា នរណានឹងអាចយកអាសាទៅចាប់យកឈួម៉ បង្វៃឡេវពៀវឲ្យយើងបាន? ។

ជៀវផៅ ឆ្លើយទទួលយកអាសា ស្រេចហើយឡើងសេះពំនួនចេញទៅតយុទ្ធនឹងឈួម៉បាន ១០ ស្នៀត, ឈួម៉ដឹងកំឡាំងនឹងតដៃជៀវផៅពុំបាន ក៏ញាក់សេះគេចថយក្រោយ , ស៊ិនគៀនលើកទាហានដេញបណ្តាយហើយចាក់កាប់សម្លាប់ពលឈួម៉ស្លាប់ជាច្រើន; ឯឈួម៉ក៏រត់ចូលទៅក្នុងស្រុក ហើយនាំពត៌មាននោះទៅជំរាបឡេវពៀវ, គេងលៀងនិយាយនឹងឡេវពៀវថា ព្រោះលោកមិនស្តាប់ពាក្យខ្ញុំទើបថ្វោះការយ៉ាងនេះ ឈួម៉ដែលអ្នកខ្លួនយកអាសាទៅធ្វើការ ហើយបែកទ័ពចូលមកវិញខូចខាតពលជាច្រើនដូច្នេះ ត្រូវតែកាត់ក្បាលឈួម៉ដោតផ្គាលទើបគួរ ។ ឡេវពៀវបានឮដូច្នោះ ( ក៏ខឹងក្តៅក្រហាយណាស់ ) តែដោយមានសេចក្តីស្រឡាញ់នាងឈួហ៊ួយមិនដែលជាភរិយា ក៏មានចិត្តអាណិតមេត្តាឈួម៉មិនបានយកទោស ។

ចំណែកស៊ុនកៀន ចុះនគណ្ឌាភាហានតាំងពួនឡោមព័ទ្ធជុំវិញស្រុក កេងជីវ, វៃ ១ បណ្ដាលកើតព្យុះយ៉ាងធំអស្ចារ្យបោកបក់រលំដងទង់ជ័យមេទ័ពរបស់ស៊ុនកៀនបាក់ដាច់ជា ២ ចំណែក ។ ហានតុងឃើញដូច្នោះក៏ជំរាបស៊ុនកៀនថា ពេលនេះមានបង្កើតអកេតុអស្ចារ្យណាស់ នេះជាប្រផ្នូលកងទ័ពរបស់យើង ទើបបាក់ដងទង់ជ័យដែលយើងកំពុងឡោមព័ទ្ធស្រុកកេងជីវទុកដូច្នេះ ខ្ញុំបាទក្រែងមានសេចក្ដីភ័យអន្ដរាយដល់លោក សុំឲ្យលើកទ័ពត្រឡប់ទៅស្រុកកាំងតាំងវិញទៅ, ចាំពេលក្រោយសុំគិតការជាថ្មីទៀត ។ ស៊ុនកៀនតបថា "យើងលើកទ័ពមកធ្វើសង្គ្រាមលើកនេះឃើញមានជ័យជំនះជាច្រើនលើក ឥឡូវនេះជិតនឹងបានស្រុកកេងជីវព្រឹកស្អែកនេះហើយ អ្នកមកបង្រួយខ្វល់ពីព្រោះខ្យល់បក់បាក់ដងទង់ជ័យប៉ុណ្ណោះមិនគួរទេ" ថាហើយក៏លើកទាហានបំពានចូលទៅដោយប្រាថ្នានឹងចំណាយកំពែងស្រុកកេងជីវឲ្យបានក្នុងពេលយប់នោះ ។ លុះដល់ពេលយប់ កេងលៀងឃើញផ្កាយ ១ ដួងធ្លាក់ពីលើអាកាស បានពិនិត្យមើលក្នុងតម្រាឃើញច្បាស់ ទើបជំរាបឡាវពៀវថា ខ្ញុំឃើញផ្កាយ ១ ដួងសៅហ្មងធ្លាក់ចុះមកយ៉ាងអស្ចារ្យ បានមើលក្នុងតម្រាឃើញថាមានគ្រោះធ្ងន់បើស៊ុនកៀន បើដូច្នេះសូមឲ្យលោកធ្វើសំបុត្រទៅសុំកងទ័ពអួនសៀវ ឲ្យលើកមកវាយទ័ពស៊ុនកៀនខួបពីខាងក្រោយ ។ ឡាវពៀវឆ្លើយថា ដែលនឹងឲ្យទៅសុំកងទ័ពអួនសៀវនោះ យើងបាន

យល់ព្រមផងហើយ  តែថាពេលនេះកងទ័ពស៊ុនគៀនឡោមព័ទ្ធជុំវិញស្រុកទាំងអស់  គ្មានចន្លោះនឹងចេញទៅបានដោយងាយ  បើយ៉ាងនេះនឹងមាននរណាយកអាសាពុះទំលាយកាន់សំបុត្រទៅបាន ។ លីកុងជាទាហានឡៅពៀវឆ្លើយទទួលយកអាសា. កេងលៀងឆ្លើយថែមថា "បើអ្នកបានទទួលយកអាសានោះខ្ញុំអរណាស់  តែអ្នកត្រូវធ្វើតាមពាក្យខ្ញុំ ។ នឹងកេណ្ឌទាហានធ្នូ ៥០០ ឲ្យទៅជាមួយ  បើអ្នកទំលាយចេញទៅបាន ចូរបែងទាហាន ២០០ ជាប្រញាប់  គឺទាហាន ១០០ ឲ្យទៅបង្កប់នៅចុងភ្នំហ៊ុសាន់  ទាហាន ១០០ ទៀត ឲ្យឡើងទៅបង្កប់នៅលើកំពូលភ្នំ  រើសយកដុំថ្មធំ ៗ បម្រុងទុកឲ្យច្រើន  ហើយប្រាប់ថាបើឃើញកងទ័ពស៊ុន-គៀនតាមច្បាំងឲ្យអ្នកនឹងទាហាន ៣០០ តទល់ហើយថយរត់ទៅ  ត្រាតែដល់ជើងភ្នំហ៊ុសាន់,  បើទាហាន ២ កងដែលបង្កប់ចាំនៅទីនោះ  បានបាញ់ធ្នូចោលដុំថ្មត្រាណា  អ្នកត្រូវអុជផាវជាសញ្ញា ៣ ដង  យើងបានឮសំឡេងផាវហើយ  នឹងលើកទាហានចេញទៅវាយខ្ទប់ពីខាងក្រោយ, បើសត្រូវមិនបានតាមអ្នកទៅទេ  ឲ្យអ្នកខំស្រូតរូតនាំសំបុត្រទៅឲ្យអួន-សៀវជាប្រញាប់ឲ្យបាន  ក្នុងពេលយប់នោះទែងងឹតណាស់  អ្នកចូរលើកទាហានស្រូតចេញទៅចុះ ។  លីកុងបានស្តាប់ក៏ទទួលពាក្យកេងលៀង បន្ទាប់នោះគ្រប់ប្រការ ហើយលាឡៅពៀវលើកទាហានធ្នូ ៥០០ បើកទ្វារទិសឯកើតចេញទៅ,.  លីកុងក៏តាំងតែច្បាំងកាប់ទំលាយដោយកំឡាំង

ខ្លួនទឹងទាហានចេញទៅចុះ ហើយបាត់ទាហាន ២០០ បង្កប់ទុកនៅទីក្នុងហ៊ុសាទ់ដា ២ កង តាមពាក្យកេងលៀងបង្គាប់ ។

ខណៈនោះ ស៊ុនកៀនឃើញទាហានក្នុងស្រុកហែកចំលាយចេញទៅបាន ក៏ឡើងសេះគាន់ងារនាំទាហាន ៣០ នាក់ដែលជិតស្និទ្ធ ស៊ុទ្ធតែជិះសេះលើកតាមទៅ, ឯសេះស៊ុនកៀនលឿនស្រួតទៅទាន់សេះលីកុងហើយស្រែកថា អ៊ីយអាឯងចេញពីក្នុងស្រុកនេះនឹងរេះរត់ទៅណា ៗ លីកុងឮហើយក៏ញាក់សេះត្រឡប់មកតតទល់ច្បាំងនឹងស៊ុនកៀនបាន ៥ ស្មៀត ហើយត្រឡប់សេះបរគេចទៅមុខ តម្រង់ត្រង់ទាហានបង្កប់នោះ, ស៊ុនកៀនក៏បរសេះតាមទៅដល់ច្រកភ្នំ, កាលមិនឃើញលីកុងក៏ញាក់សេះត្រឡប់មកក្រោយ រកទាហានរបស់ខ្លួនទាំង ៣០ នាក់វិញ ស្រាប់តែឮសំឡេងឃោះគងខ្ទង់ស្គរលើកំពូលភ្នំ ដុំថ្មធំៗក៏ធ្លាក់ចុះមកព្រោងព្រាត ទាហានដែលបង្កប់នៅជើងភ្នំក៏បាញ់ធ្នូបម្រះមកទៀត, ស៊ុនកៀនទឹងសេះនោះ ត្រូវត្រូញនឹងដុំថ្មបែកហូរឈាមជោកប្រឡាក់ពេញអស់ទាំងខ្លួន សេះនឹងមនុស្សក៏អស់ជីវិតក្ស័យនៅទីច្រកភ្នំនោះ; កាលស៊ុនកៀនស្លាប់ អាយុបាន ៣៦ ឆ្នាំគត់ ។

លីកុងលុះឃើញដូច្នោះ ក៏វាត់ទាហានទៅស្ទាក់សម្លាប់ទាហានសេះស៊ុនកៀនស្លាប់ទាំង ៣០ នាក់ ហើយឲ្យអុជផាវធំជាសញ្ញា ៣ ដងកេងលៀងបានឮច្បាស់បាត់ឲ្យកេងអួន ហងច ឈួម៉ លើកទាហានចេញ

ទៅជា ៣ ផ្លូវ ទាហានស៊ុនកៀនមិនទាន់ដឹងខ្លួនក៏បែកប្រពាក់ប្រពូន របួសស្លាប់ជាច្រើន ។

ឯអ៊ុយកាយ ដែលនៅថែរក្សាទូកចម្បាំងនោះ ដល់បានឮសំឡេងហោកញ្ជ្រៀវគឹកកង ក៏លើកទាហានឡើងគោកនឹងទៅជួយ ស្រាប់តែប្រទះនឹងកងទ័ពហាងច ចៅហ្វាយស្រុកកាំងហែលើកទៅទល់ពីមុខ ក៏តយុទ្ធគ្នាអស់ ៦ ស្ទៀត អ៊ុយកាយចាប់ហាងចបាន ។

ខាងចៀវផៅ ស៊ុនសិកលើកទ័ពទៅតាមស៊ុនកៀន ស្រាប់តែជួបប្រទះនឹងលីកុង ចៀវផៅច្បាំងនឹងលីកុងបាន ៤ ក្លួង, ចៀវផៅចាក់លីកុងនឹងខ្លួនធ្លាក់ពីលើសេះស្លាប់ ។ ក្នុងពេលយប់នោះ ទាហានឡេវពៀវនឹងទាហានស៊ុនកៀនច្បាំងប្រកាប់គ្នាស្លាប់ជាច្រើន, ឯទាហានដែលលីកុងនាំទៅនោះ ក៏យកសពស៊ុនកៀននាំទៅជូនឡេវពៀវ, ដល់ពេលព្រឹកឡើងទាហានឡេវពៀវក៏នាំគ្នាចូលទៅក្នុងស្រុក ។

ឯស៊ុនសិកនឹងចៀវផៅ ដល់មិនបានជួបប្រទះនឹងស៊ុនកៀន ហើយក៏នាំសេនាទាហានដែលបាក់បែកទាំងប៉ុន្មាននោះទៅតាំងទីនៅដំបន់ហានស៊ុយ ។ ពេលនោះ មានទាហានម្នាក់នាំពត៌មានទៅប្រាប់ស៊ុនសិកថា: ស៊ុនកៀនជាបិតាអ្នកនោះត្រូវព្រួញស្លាប់នៅទីច្រកភ្នំហ៊ុសានពីយប់មិញទៅហើយ សពនោះពួកទាហានស្រុកកេងជីវនាំចូលទៅជូនឡេវពៀវហើយ ។

សុិនសឹកដឹងដំណឹងច្បាស់ ក៏ពោកព្រាស់ខ្លួនផ្ដួលយំសោកស្រណោះបិតាជាអនេក លុះស្ងាត់សេចក្ដីសោកសៅហើយ ក្រោកឡើងនិយាយនឹងពួកអាហានទាំងពួងថា ឥឡូវសពបិតារបស់យើងនៅក្នុងស្រុកគេឯងជីវឯណោះ បើយើងនឹងលះបង់មិនច្បាំងយកស្រុកនេះឲ្យបាន ហាក់ដូចជាគ្មានសេចក្ដីកតញ្ញូចំពោះបិតា ។ អុិយកាយតបថា ខ្ញុំចាប់ខ្លួនហាងចចៅហ្វាយស្រុកកាំងវៃបានយកមកទុកក្នុងកងទ័ព បើដូច្នេះ ចាំប្រើបំរើចូលទៅឲ្យដំណឹងឡេវពៀវស៊ិន បើគេព្រមបញ្ជូនសពបិតាអ្នកមកឲ្យយើង សុំយើងបញ្ជូនខ្លួនហាងចទៅឲ្យគេវិញ ឯការដែលធ្វើសង្គ្រាមនឹងគ្នានោះ ត្រូវបង្អង់ទុកឲ្យជាមេត្រីនឹងគ្នាតទៅ បើបានការដូច្នេះ ត្រូវលើកទ័ពត្រឡប់ទៅស្រុកកាំងតាំងវិញ ។

ហួនកាយនិយាយឡើងថា ខ្ញុំនឹងឡេវពៀវស្គាល់គ្នាតាំងពីតូចមក ខ្ញុំនឹងសុំយកអាសាទៅនិយាយនឹងឡេវពៀវព្រមតាមពាក្យអុិយកាយថានោះ, សុិនសឹកបានស្ដាប់ហើយមានសេចក្ដីត្រេកអរជាពន្ទឹក ហើយចាត់ឲ្យហួនកាយចេញទៅនិយាយការនោះ, កាលហួនកាយទៅដល់ឡេវពៀវហើយនិយាយថា ឥឡូវនេះសុិនសឹកមិនបានធ្វើសង្គ្រាមនឹងលោកតទៅទៀតទេ នឹងសុំយកតែសពសុិនកៀនជាបិតាទៅវិញ បើខាងលោកយល់ព្រមឲ្យហើយ នឹងបញ្ជូនខ្លួនហាងចដែលចាប់បាននោះមកលោក ហើយសុិនសឹកនឹងលើកទ័ពត្រឡប់ទៅស្រុកតែម្ដង ។ (មានត)

# ព្រះរាជពង្សាវតារប្រទេសកម្ពុជា

## ភាគទី ២

### សម័យនគរធំ

ទេពពិទូរ ឈឹម-ក្រសេម រៀបរៀង

(តមក)

---

## ព្រះបាទអនុរុទ្ធតិតភាយក្រុងលវបុរៈ

ព្រះបាទអនុរុទ្ធមិនមែនជាក្សត្រដោយព្រះជាតិទេ តែដោយហេតុមានស្នាដៃខ្លាំងពូកែ ក៏បានជាព្រះរាជាគ្រប់គ្រងប្រជាជន ជាតិមន និងជាតិភូមារម្មញ្ញ តាំងព្រះរាជធានីនៅភុកាម (បុណ្ណកាម) ក្នុងកាល ព. ស. ១៥៨៣ ដល់ ១៥៩៥ ។ ព្រះបាទអនុរុទ្ធនេះជាអ្នកជ្រះថ្លាក្នុងព្រះពុទ្ធសាសនាយ៉ាងខ្លាំងក្លា, តាំងពីពេលព្រះអង្គបានឡើងគ្រងរាជ្យ ១ហើយ ក៏មានប្រាថ្នាយ៉ាងខ្ពស់ក្នុងការផ្សាយអំណាចនិងផ្សាយព្រះពុទ្ធ-សាសនា ទំនងដូចព្រះបាទធម្មាសោករាជនៅប្រទេសឥណ្ឌា ។ តអំពីនោះ ទ្រង់លើកទ័ពទៅវាយពួកអនុប្រទេសប៉ែកខាងលើ បានជាច្រើនប្រទេសមកជាចំណុះ ។ ទ្រង់កាលវាយបានអនុប្រទេសជាច្រើន គ្មានអ្នកណាទប់ទល់បានដូច្នេះហើយ ក៏រឹតតែមានព្រះរាជហឫទ័យក្លាហានខ្លាំងឡើង ទើបគិតលើកទ័ពមកវាយបច្ចន្តរដ្ឋរបស់ប្រទេសកម្ពុជាទៀត ។

កាលនៅថ្ងៃ ១៣ កើតខែមិគសិរ ឆ្នាំថោះ ព. ស. ១៥៥៨ ព្រះបាទអនុរុទ្ធសោយរាជ្យបាន ៦ ឆ្នាំ ក៏លើកទ័ពធំចូលក្រុងដែនរដ្ឋទ្វារាវតី ដោយបំណងនឹងវាយក្រុងលវបុរៈ ហើយនឹងក្រុងហរិភុញ្ជ័យ ។ ព្រះចន្ទ្រជោតិអ្នកគ្រងនគរលវបុរៈទ្រង់ជ្រាប ទ្រង់បានប៉ាន់មើលកំឡាំងសឹកក៏ទ្រង់ជ្រាបច្បាស់ថា បើចំពោះតែកំឡាំងទ័ពក្រុងលវបុរៈនោះ ពុំអាចនឹងទប់ទល់កំឡាំងទ័ពបច្ចាមិត្របានទេ វៀរលែងតែមានកងទ័ពខាងព្រះមហានគរមកជួយផង, បើទ័ពខាងព្រះមហានគរ (គឺទ័ពព្រះបាទសូរ្យវរ័ន្ទ) មកជួយទាន់នោះទ័ពបច្ចាមិត្រគ្មានផ្លូវនឹងឈ្នះទេ តែនេះទ័ពបច្ចាមិត្រចូលមកទៀបដល់ក្រុងហើយ ទំរាំតែឲ្យដំណឹងទៅដល់ព្រះមហានគរ នឹងទំរាំតែកងទ័ពខាងមហានគរលើកមកដល់ ក្រុងលវបុរៈគង់ខូចទៅមុន, ហេតុនេះ ទើបត្រាស់ឲ្យប្រជុំគណៈសេនាបតី ។ កាលទ្រង់ថ្លែងព្រះរាជយោបល់សព្វគ្រប់ហើយ គណៈសេនាបតីក៏យល់ព្រមតាមព្រះរាជតំរិះ, លំដាប់នោះ ទ្រង់ឲ្យតែងព្រះរាជសារ ១ ច្បាប់ ឲ្យសេនាបតីធំនាំទៅថ្វាយព្រះបាទអនុរុទ្ធ ។ ទំនងសេចក្ដីក្នុងព្រះរាជសារនោះថា "សូមឲ្យល្អងធូលីព្រះបាទរង់ ៧ ថ្ងៃសិន, ក្រុងលវបុរៈនឹងតស៊ូ ប្ដូរនឹងញ៉មពាញ់ដោយសុភាព, ព្រះអង្គអាចនឹងទ្រង់ជ្រាបបានក្នុងរវាង ៧ ថ្ងៃខាងមុខនេះ" ។

ដើម្បីជៀសវាង កុំឲ្យមានសឹកសង្គ្រាមក្នុងប្រទេស ព្រះចន្ទ្រជោតិក៏ត្រាស់ឲ្យភ្នាក់ងារផ្សេង ៗ រៀបក្បួនសម្រាប់ហែព្រះនាង កែវប្រពាឡ ដ៏ជាព្រះជេដ្ឋភគិនីនៃព្រះអគ្គទេវី និងហែព្រះរាជសារទៅថ្វាយព្រះបាទអនុរុទ្ធ សុំចងសម្ពន្ធមេត្រី ។

លុះដល់ថ្ងៃគំរប់ ៧ ក្បួនហែក៏ចេញអំពីក្រុងលវបុរៈឆ្ពោះទៅកាន់ទីជំរំទ័ពនៃព្រះបាទអនុរុទ្ធ ដោយមានអគ្គសេនាបតី ១ នាក់ជាអ្នកតំណាងរាជការទៅផង ។ ព្រះបាទអនុរុទ្ធបានទតព្រះរាជសារសូមចងសម្ពន្ធ-មេត្រី និងទតព្រះរូបព្រះឆោមព្រះនាងកែវប្រពាឡដែលទុកជាចំណងសម្ពន្ធភាព ក៏ទ្រង់មានសេចក្តីបដិព័ទ្ធជាយ៉ាងក្រៃពេក ទើបទ្រង់ទទួលព្រះនាងទុកហើយត្រាស់ឲ្យតែងរាជសារតប ស្រេចហើយទ្រង់ឲ្យសេនា-បតីរបស់ព្រះអង្គ នាំព្រះរាជសារព្រមទាំងរាជបណ្ណាការ គឺដំរី ១០០ សេះ ១០០ ទៅថ្វាយព្រះចន្ទ្រជោតិ ហើយស្តេចលើកទ័ពត្រឡប់ព្រះនគរ ត្រាស់ឲ្យធ្វើពិធីអភិសេកព្រះនាងកែវប្រពាឡជាឯកអគ្គមហេសី(១) ។ អំពីនោះមក ប្រទេសភូមានិងប្រទេសកម្ពុជាក៏បានជាមិត្រនឹងគ្នា ភូមាលើកលែងមករុករានប្រទេសកម្ពុជាទៀត ។

---

១ ព្រះនាងកែវប្រពាឡ តទៅមានព្រះរាជឱរស ១ អង្គព្រះនាមឥន្ទរក្សោ ។

ក្រោយនេះ ព្រះចន្ទ្រជោតិ បានយកសេចក្ដីក្រាបបង្គំទូលព្រះបាទសូរ្យវង្សទី ១ តាមរបាយការណ៍ដែលមានមកហើយនោះ ដើម្បីទ្រង់ជ្រាបសព្វគ្រប់ប្រការ ។ ព្រះបាទសូរ្យវង្សទ្រង់សព្វព្រះរាជហឫទ័យក្នុងកិច្ចការដែលព្រះចន្ទ្រជោតិបានបំពេញមកហើយជាយ៉ាងក្រៃពេក ត្រាស់សរសើរព្រះយោបល់នយោបាយរបស់ព្រះចន្ទ្រជោតិថា "ប្រសើរណាស់ ដែលចេះរកប្រចៀសសង្គ្រាមដែលមកដល់ចំពោះមុខហើយឲ្យថយទៅបានដោយមន្តកាមទេព" ហើយត្រាស់ថា "ត្រូវរៀបចំក្រុងលវែកឲ្យមាំមួន ដើម្បីទប់ទល់សឹកសត្រូវបានទៅក្នុងអនាគត" ។

មកក្នុងឆ្នាំ ព. ស. ១៩៧៤ (គ ស ១០៣០) ព្រះបាទសូរ្យវង្សបរមរាជាធិរាជ ទ្រង់បានតែងរាជទូត ឲ្យនាំព្រះរាជសារនូវរាជបណ្ណាការទៅសុំចងសម្ពន្ធមេត្រីភាព នឹងស្ដេចក្រុងចិន ។ ខាងស្ដេចចិនក៏ព្រមទទួលចងសម្ពន្ធភាពតាមផ្លូវការ ហើយទ្រង់បានតែងរាជទូតឲ្យនាំរាជសារនូវរាជបណ្ណាការតបមកវិញ ។ ប្រទេសកម្ពុជាប្រែនយោបាយចងសម្ពន្ធមេត្រីភាពនឹងប្រទេសចិនរាប់ជាត្រាទី ៦ ក្នុងរជ្ជកាលនេះ ។

ចំណែកខាងតំណៀ ក្នុងរជ្ជកាលនេះ ក៏មានការទាក់ទងគ្នាទៅវិញទៅមក ដូចក្នុងរជ្ជកាលព្រះបាទជយវរ្ម័នទី ៩ តែមិនប្រាកដជាបានចងសម្ពន្ធមេត្រីភាព តាមផ្លូវការដែរ ឬយ៉ាងណា ។

(មានត)

សាវតារវត្តចានយ

នៅឃុំអង្គាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ

## លោកមេឃុំ ឡុង – អ៊ុប

ជាអាចារ្យវត្តនេះ រៀបរៀង

(រក្សាលេខ ១)

( គ ចប់ )

---

# អធិប្បាយអំពីរឿងឆ្លងបុណ្យ

ចំនៀមចំលាប់ដែលឆ្លងបុណ្យនេះ ខ្ញុំបានឃើញសាស្ត្រា ១ ឈ្មោះ "សាស្ត្រាចំឡងបុណ្យ" ៗ ក្នុងសេចក្តីសាស្ត្រានោះ មានដំណាលថា: គឺ: ដូចបានព្រេងរៀងមក កាលណោះ មានជន ២ នាក់ (ប្តីនឹងប្រពន្ធ) មានឈ្មោះមិនប្រាកដ នៅស្រុកឥន្ទបត្តបុរីមហានគរ បានធ្វើបុណ្យ ១២ ឆ្នាំ ហើយមិនទាន់បានឆ្លង, ថ្ងៃ ១ បុរសជាប្តីគិតនឹងប្រពន្ធថា "ភានើយ ! បុណ្យដែលយើងធ្វើនេះ ១២ ឆ្នាំហើយ តែមិនទាន់រៀបក្រយាឆ្លងបុណ្យដល់ម្តងសោះ ហេតុនេះយើងនឹងគិតធ្វើនំចំណីដើម្បីឆ្លងបុណ្យយើងនេះឲ្យហើយ ដ្បិតសង្ខារយើងនេះមិនទៀង ស្លាប់ថ្ងៃនេះក៏មិនដឹង ស្អែកក៏មិនដឹង ខានស្អែកក៏មិនដឹង" ៗ ប្រពន្ធឮហើយក៏ត្រេកអរ បានដាំបាយវេចឲ្យប្តីដើម្បីទៅរកចុះសរបេះបន្លែ ៗ ប្តីនោះចេញទៅដោយសេចក្តីរីករាយសប្បាយ ច្រៀងហួចត្រចាស់អង្រួចបណ្តើរទៅតាមផ្លូវ លេចវាលចូលព្រៃ

ឆ្ងាយបន្តិចទៅ បានឃើញដើមឈើ ១ ធំមានម្លប់ត្រសាយសាខា បុរសនោះក៏ចូលទៅដេកក្រោមដើមឈើនោះលក់ទៅ ។

ក្នុងសាស្ត្រានោះ មាននិយាយថា: កាលនោះព្រះឥន្ទ្របើស្តេចចតុលោកបាល ឲ្យចុះមកមើលឋានមនុស្សលោកនេះ បើឈ្មោះណាធ្វើអំពើបាប ឲ្យកត់ទឹងបញ្ជីស្បែកខ្លា បើឈ្មោះណាធ្វើបុណ្យ ឲ្យកត់ទឹងជម្ព្វាមាស ។ លុះស្តេចចតុលោកបាល បានដើរត្រាច់ប្រទះជួបនឹងបុរសដែលកំពុងដេកលក់មិនដឹងខ្លួនក្រោមដើមឈើធំនោះក៏សួរថា "បុរសឯងមករកអ្វី" ។ ព្រលឹងបុរសនោះបាននិយាយនឹងស្តេចចតុលោកបាលដូចយើងសព្វថ្ងៃហៅថាយល់សប្តិថា "ខ្ញុំមករកទុសបេះបន្ទៃទៅធ្វើបុណ្យធ្ងន់ ដ្បិតធ្វើបុណ្យមក ១៦ ឆ្នាំហើយមិនទាន់បានធ្ងន់" ។ ស្តេចចតុលោកបាលស្តាប់ហើយត្រេកអរ បានស្រូបព្រលឹងបុរសនោះទៅឋានតាវត្តិង្ស នាំទៅក្រាបទូលព្រះឥន្ទ្រតាមដំណើរ ។ លុះព្រះឥន្ទ្របានឃើញបុរសនោះហើយ ក៏សួរទៅបុរសនោះ ៗ ឆ្លើយទូលព្រះឥន្ទ្រតាមដំណើរដែលខ្លួនបានធ្វើបុណ្យ ។ លុះព្រះឥន្ទ្របានស្តាប់បុរសនោះហើយក៏ត្រេកអរបាននិយាយប្រាប់បុរសនោះថែមទៀតថា "មហាបុរសអើយអ្នកដែលបានធ្វើបុណ្យហើយបានធ្ងន់នោះប្រសើរណាស់, អ្នកដែលធ្វើបុណ្យហើយមិនធ្ងន់ បុណ្យនោះនាំទៅឯណាមិនរួចទេ; អញនឹងនិយាយឲ្យបុរសឯងស្តាប់: កាលណោះមានបុរស ១ នាក់ ដាំដើមជ្រៃ

ហើយមិនបានធ្ងន់ ស្លាប់ទៅៗកើតជាកាដសីហ៍ទៅស៊ីស្មៅតែក្រោមម្លប់ ដៃដែរនោះ ចេញទៅរកស៊ីឯណាទៀតពុំរួច ។ មានបុរស ១ ទៀត ជីកអណ្តូងជីកស្រះឲ្យគេផឹកទឹក ហើយមិនបានធ្វើបុណ្យធ្ងន់ ស្លាប់ទៅៗ កើតជាមនុស្សទៀត ជីកអណ្តូងមិនចេញទឹក ។ បុរស ១ ទៀត ចេញទៅរៀនសិល្បសាស្រ្តអំពីអាចារ្យ ចេះស្រេចកាលណាមិនបានធ្វើពិការ បូជាដល់អាចារ្យនោះ លុះស្លាប់ទៅ ៗ កើតជាមនុស្សទៀតរៀនរបៀន សិល្បសាស្រ្តអ្វីៗក៏មិនចេះមិនចាំ ៗ ហើយក៏មិនពូកែធុតធាប់ ។ មានព្រាហ្មណ៍ ១ ទៀត មានកូនច្រើនណាស់ តែមិនបានកោរសក់បង្កក់ធ្មប ធ្វើធ្មេញលេញលីខបួលម្លប់បង្រ្កិបការឲ្យកូន ស្លាប់ទៅ ៗ កើតជាព្រាហ្មណ៍ទៀត គ្មានកូន ១ សោះ ទៅរកសុំកូនគេៗមិនឲ្យថែមទៀត ហេតុតែមិនបានធ្វើកិច្ចឲ្យកូន ,, ។

លុះព្រលឹងបុរសនោះ បានស្តាប់ព្រះឥន្ទ្រចប់សព្វគ្រប់ហើយ ក៏លាព្រះឥន្ទ្រត្រឡប់មកវិញ ចូលមកក្នុងរូបដែលដេកលក់នោះក៏ភ្ញាក់ឡើង ។ បុរសនោះគិតថា " អញដេកលក់អម្បាញ់មិញនេះយល់សប្តិឃើញល្អណាស់ ព្រលឹងអញបានទៅឋានសួគ៌ ស្តាប់ធម៌របស់ព្រះឥន្ទ្រអំពីរឿងធ្វើបុណ្យនេះប្រសើរណាស់ " ។ កាលបុរសនោះគិតដូច្នោះហើយ ក៏រក ទសបេះបន្ទៃត្រឡប់មកផ្ទះវិញ និយាយប្រាប់ប្រពន្ធនឹងអ្នកជិតខាងតាម

ដំណើរដែលខ្ញុំយល់សព្វនោះ ។ ពាក្យទំនៀមទំលាប់ថាជូនបុណ្យ កំមានជាប់តាំងនោះរៀង ៗ មក ។

ឯរបៀបជូនបុណ្យ ដែលខ្ញុំបានឃើញអ្នកដែលធ្វើបុណ្យតាមទំនៀមទំលាប់អ្នកស្រុកដែលធ្វើត ៗ គ្នាមកនោះ: មានរបៀបទំ ៤ ផ្លែឈើ ៤ ស៊ីង ៤ ទៀន ៤ ដើម ផ្តិលទឹក ៤ មានប្រេងម្សៅដាក់តែង ១ គូ, លុះលោកសូត្រសត្តបករណាភិធម្ម នឹងធម៌តិកេកចប់ហើយ អាចារ្យអុជទៀន ៤ ដើម និមន្តលោកសូត្រពាហុទេវជូនបុណ្យ, លុះចប់ធម៌ពាហុទេវហើយ អាចារ្យប្រគេនដើងស្លាបតែង ២ ទៅលោក ៗ ទទួលយកមកអធិស្ឋានជូន ហើយប្រគល់មកឲ្យអាចារ្យវិញ ទើបអាចារ្យលើកតែងទាំងពីរឡើងបញ្ចេញវចីភេទថា " ទានាបុណ្យបរិ - បូណ៌ជល់ស្មោះសរ ជាមហាបុញ្ញា នៃអ្នកដើមការ សទ្ធាសោរដ្ឋា អ្នកនោះវិសោ វិសុទ្ធប្រែម-ប្រិយ ៗ មានចិត្តស្ម័គ្រស្មោះ ប៉ុនប៉ងចំពោះ គប់អង្គម្ចាស់ថ្លៃ ជាទីពឹងពាក់ ពុំនាក់អាស្រ័យ ព្រះស្រីរត្នត្រ័យ សព្វថ្ងៃនេះណា ៗ អ្នកដើមការគិត តែងនឹងព្រួយចិត្ត អាណិតអាត្មា រលង់រលែក សង្វេគអនិច្ចា ខ្លាចក្រែងសង្សារ មិនទៀងទាត់នៅ ៗ ដូចដើមពាំង ដុះទៀបមាត់ច្រាំង ទឹកហូរជ្រោលជ្រៅ របេករបេះ រលះច្រាំងទៅ ពាំងនោះនៅពុំបានឡើយណា ៗ រលើងរលំ សាត់ទៅតាំងគុម្ព ក្រឡាប់ផ្កាប់ផ្ងារ កល់រូបប្រុសស្រី សព្វថ្ងៃនេះណា គង់ធម៌លោកថា ចបមាព្យោះហោង ៗ

ហេតុនេះគួរគិត គួរតែតាំងចិត្ត កុំឲ្យមានហួង ធ្វើបុណ្យឲ្យទាន ជាស្ពាន
ចំឡង នាំរូបរួចរួង ពីអកុសល ៗ អន្ទយជញ្ជូង ដេកហើយរំពឹង គន់
គិតឲ្យយល់ សក់ល្អដៀតប្រែង ទឹករំងដៀតខ្យល់ កម្មអកុសល កល់រូប
ឥតថ្លៃ ៗ លោកថាកំណើត កក់ផងតែងកើត ពីទឹកឯងឯង បើនឹងលាង
កក់ ឲ្យជ្រះឲ្យថៃ ឲ្យជ្រះមានតែ ទឹកទើបលាងជ្រះ ៗ អកុសល
អំពើអំពល់ ពៀរពុំស្រឡះ វាមានតែចិត្ត គំនិតមោម្ហះ មិនតាមធម៌ព្រះ
បន្ទូលទេសនា ៗ ថាបើនឹងផ្តាច់ បាបពៀរសារម្រេច លាលាងវេរ
មានប៉ុន្តែចិត្ត គំនិតសទ្ធា ចែកចាយទ្រព្យា ធ្វើបុណ្យឲ្យទាន ៗ
ទោះមានទោះខ្សត់ ទោះទៀយទោះហត់ ទោះអត់ទោះឃ្លាន ទោះបាយ ១
វែក សំឡ ១ ចាន ធ្វើបុណ្យឲ្យទាន ទាន់ខ្លួនរស់នៅ ៗ មានទ្រព្យតិចតួច
មានកាលចោរលួច ភ្លើងឆេះអស់ទៅ កាលខ្លួននៅរស់ របស់គង់នៅ
ដល់ខ្លួនស្លាប់ទៅ អសារសូន្យសោះ ៗ កូនចៅនៅក្រោយ គេធ្វើ
បុណ្យឲ្យ គេនឹកតែឈ្មោះ កន្ទេលដាច់ដាយ ឆ្នាំងបាយទំលុះ កាំបិត
បន្ទោះ បញ្ចុះកំពង់ ៗ គ្រឿងប្រាក់គ្រឿងមាស គ្រឿងស្ពាន់គុជាស
ដែលខ្លួនបំរុង គេថាទ្រព្យគេ មិនយកទៅបួង គេទុកបំរុង ចេញចាយ
ចែកគ្នា ៗ ហេតុដូច្នោះនៃ កល់រូបប្រុសស្រី គួរគិតអនិច្ចា ស្លាប់ទៅ
ជាខ្មោច អសោចវេទនា មិនមានអ្នកឯណា កំដរទៅផង ៗ មានតែ
សីលទាន នោះទើបនឹងបាន នាំរូបរួចហោង ជាទូកជាក្ពារ ចេញចែវចួង

នាំរូបរំលង ក៏លើផ្កាសង្ខារ ៗ ហេតុនេះគួរគិត ឲ្យមានសុចរិត គ្រប់អង្គកត្តា ទើបទីនិព្វាន គឺនគរវេហា ទៅដល់បាននមហា · និព្វាននោះហោង" ៗ

រូបអាចារ្យថា អនុមោទនា លោកអើយ! ៗ

អ្នកបុណ្យទទួលថា សាធុ ៗ ៣ ដង ៗ

ពន្យាតែវត្តប្រទេយ ទំនើពិធីកសាងវត្ត, ពិធីបញ្ចុះសីមា, ពិធីធ្វើបុណ្យ ចប់ដោយសេចក្ដីសង្ខេបតែប៉ុណ្ណោះ ៗ

សូមជូនចូលមកដល់ក្រុមជំនុំទំនៀមទំលាប់ខ្មែរ នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ បើលោកពិនិត្យទៅឃើញថាត្រូវផាប់លេខថ្នាក់ណា, ខ្ញុំបាទសូមទទួលរង្វាន់ជាប្រាក់តាមថ្នាក់នោះ បើពុំប្រាកដសូមស៊ីញ៉េឈ្មោះជូនទុកខាងក្រោមនេះ ៗ

ថ្ងៃ ៨ ខែមេសា ឆ្នាំ ១៩៤៩

អាចារ្យ ខូង - អ៊ូច

បេះប្រសើរជាងមិនបេះ

ទំនៀមណាដែលជាមិនគួរកាន់
ទំនៀមនោះគេគ្រាន់តែសិក្សា
ឲ្យបេះបាំដូចបន្លាឱសថា
គង់ពេលណាឲ្យផលដល់ពុទ្ធាន ៗ

យូរ - អ៊ុង

គតិបណ្ឌិត

# លោកប៉ុន - ប៉ាត់ អតីតតំណាងរាស្ត្រ

រៀបរៀង

យើងសូមបង្អោនកាយ សំដែងសេចក្ដីគោរព រឭកនឹកដល់ព្រះគុណ របស់រត្នបុរសទាំងឡាយក្នុងសាកលលោកនេះ ដែលជាអ្នកប្រាជ្ញខាងវិទ្យាសាស្ត្រ, អ្នកប្រាជ្ញទាំងនោះ បានកសាងលោកឲ្យមានសេចក្ដីសុីវិល័យ នឹង វឌ្ឍនធម៌គ្រប់ជំពូកគ្រប់បែបគ្រប់យ៉ាង ទុកមកឲ្យយើងរាល់គ្នាគ្រប់ជាតិគ្រប់ភាសា បានឃើញបានស្គាល់ នូវស្នាដៃស្នាមគំនិតរបស់លោក រហូតមកដល់សព្វថ្ងៃនេះ ។

ឯវិទ្យាសាស្ត្ររបស់អ្នកប្រាជ្ញទាំងឡាយនោះ ហួសវិស័យយើងរាល់គ្នា ដែលជាអ្នកមិនធ្លាប់គិតមិនធ្លាប់នឹក ឃើញថារបស់ទាំងឡាយនោះមិនគួរនឹងកើតឡើងបាន ទៅជាកើតឡើងបាន ដោយអាស្រ័យថ្វីគំនិតរបស់លោកអ្នកប្រាជ្ញទាំងឡាយនោះ ដូចយ៉ាងលោកខំប្រឌិតនូវគ្រឿងចក្រផ្សេងៗ មានរថយន្តរថភ្លើងនិងគ្រឿងអាកាសយាន មាននាវាបើកបរលឿនលើទឹកមុជដែកទឹកដែកដី ( ដូចម្ដា ) និងគ្រឿងប្រដាប់ខាងវិទ្យុទូរស័ព្ទទូរលេខផ្សេងៗ ជាដើមក្ដី ផ្លូវឯណាដែលធ្លាប់ធ្វើដំណើរទៅរាប់ខែក៏អាចបន្ថយឲ្យទៅជារាប់ថ្ងៃ, ផ្លូវឯណាដែលធ្លាប់ធ្វើដំណើររាប់ថ្ងៃក៏ក្លាយទៅជារាប់ម៉ោងទៅវិញបាន ។ល។ ។

ឯចំណែកខាងវិជ្ជាពេទ្យសាស្ត្រ នោះសោតទៀត ក៏កាន់តែចំរើនកើនឡើង ៗ ចេញជាលំដាប់រាល់ឆ្នាំ លោកខំគិតប្រឹងប្រែងជួយទ្រទ្រង់ដល់ជីវិតមនុស្សលោក ឲ្យមានជីវិតរស់នៅបានវែង មានការវះកាត់ប៉ះពារប្រឆាំងទុះនឹងគ្រឿងពិនិត្យពិសោធសាកសម្ផ្លានរកហេតុផលឲ្យដឹងជាក់លាក់ ដើម្បីនឹងប្រកបឱសថទៅតាមជម្ងឺរោគ , លោកខំកសាងក្បួនតម្រានឹងវិធីបង្ការរោគ បំបាត់រោគដែលកើតមានឡើងហើយ ឲ្យអន់ថយខ្សោយចុះ កុំបីឲ្យកើតមាន ហើយប្រឹងស្រាវជ្រាវរកនូវវត្ថុធាតុផ្សេង ៗ យកមកផ្សំប្រកបជាឱសថ ដើម្បីនឹងជួយជីវិតមនុស្សឲ្យបានមានអាយុវែងតទៅ (ល) ។

រឿងនេះ យើងមិនបាច់ពោលឲ្យវែងតទៅទៀតទេ ព្រោះអស់លោក-អ្នកទាំងឡាយ សឹងបានជ្រាបស្រាប់ហើយនូវអារ្យធម៌នឹងវឌ្ឍនធម៌នឹងសេចក្ដីលំបាកក្នុងការស្រាវជ្រាវរករបស់អ្នកប្រាជ្ញ, ការស្រាវជ្រាវរកនូវអារ្យធម៌ នឹង វឌ្ឍនធម៌ជាគ្រឿងវិទ្យាសាស្ត្រដែលកើតមានក្នុងលោកដល់សព្វថ្ងៃនេះ នោះមិនមែនជាការងាយទេ ពុំមែនរកឃើញដោយឆាប់រហ័សទៅតាមចិត្តប៉ងនឹកនោះទេ, គេបានអាស្រ័យសេចក្ដីព្យាយាមយ៉ាងខ្លាំងក្លា គេបានប្រើពេលវេលារាប់ពាន់ឆ្នាំ ធ្វើឲ្យស្លាប់មនុស្សក្នុងការល្បងលមើលនូវវិទ្យាសាស្ត្រផ្សេង ៗ ស្លាប់អស់ជាច្រើននាក់ ។ វិទ្យាសាស្ត្រមួយ ៗ ដែលសម្រេចឡើងនោះ គេបានប្រើអស់អ្នកប្រាជ្ញជា

ប្រឹងតំណាអាយុទើបសម្រេចឡើងបាន ។ ការខំគិតខំលៃខំស្ទង់ស្ទង់រកនូវវត្ថុធាតុនិងវត្ថុធម្មជាតិ ដើម្បីនឹងយកមកផ្សំប្រកបនូវវិទ្យាសាស្ត្រផ្សេងៗនោះ លោកក៏ខំទ្រាំតស៊ូអត់អាហារនិងដំណេកក៏សឹងមាន, ឯការឆ្ងាញ់នឹងការសប្បាយរបស់លោក លោកយកការរកឃើញនេះ ជាគ្រឿងឆ្ងាញ់គ្រឿងសប្បាយរបស់លោក ។ ហេតុទាំងនេះឯងដែលបណ្ដាលឲ្យយើងមានបីតិគិតនឹកដល់ព្រះគុណរបស់លោក ដែលលោកមានព្រះគុណលើសាកលលោកទាំងមូលនេះ; ដោយលោកខំប្រឹងប្រែងយកជីវិតរបស់លោក មកប្រកួតការស្វះស្វែងស្រាវជ្រាវរកនូវវិទ្យា-សាស្ត្រផ្សេងៗ ប្រយោជន៍ទុកជាកេរ្តិ៍មត៌កសម្រាប់សាកលលោក ដើម្បីនឹងឲ្យយើងពល់គ្នាបានទទួលក្រេបជញ្ជក់យកនូវស្នាមគំនិតរបស់លោក ជាគ្រឿងរីករាយសប្បាយដល់ពលលោកទាំងមូល ។

ហេតុនេះ យើងសូមបង្អោនកាយរបស់យើងចូលកាន់មរណសញ្ញា ចំពោះដួងវិញ្ញាណក្ខន្ធរបស់លោកអ្នកប្រាជ្ញទាំងឡាយនោះ ដែលបានលាចាកអំពីលោកនេះទៅ ទុកសល់នៅតែស្នាមគំនិតជាកេរ្តិ៍មត៌កទាំងឡាយឲ្យដល់ពលលោក យើងទាំងអស់គ្នានេះ សូមឲ្យលោកបានទៅសោយសេចក្ដីសុខគ្រប់ប្រការកុំបីឃ្លៀងឃ្លាតឡើយ ។

យើងមានសេចក្ដីតក់ស្លុតខ្វល់ញាប់ញ័រក្នុងហទយ : ( បេះដូង ) ដោយមានសេចក្ដីនឹកស្ដាយស្រណោះ ដល់ស្នាមគំនិតនៃវិទ្យាសាស្ត្រ

របស់គ្រូបុរាណទាំងឡាយនោះលោកនោះ ដែលលោកទំរាវរកបាន កើតឡើងដោយគម្រោងដូចយើងបានរៀបរាប់ខ្លះមកខាងលើនេះ គឺយើងបានទទួលដំណឹងខ្លះតាមវិទ្យុនិងសារពត៌មានខ្លះ ថាមានអ្នកប្រាជ្ញខាងប្រឌិតនូវគ្រឿងយុទ្ធសាស្ត្រផ្សេង ៗ បានបំរើនកើនឡើងនូវកម្លាំងអានុភាព គឺគ្រឿងប្រហារប្រល័យលោក មានគ្រាប់បែកបរមាណូនិងអ៊ីត្រូហ្សែនជាដើមនោះ; នាំឲ្យយើងមានសេចក្ដីតូចចិត្តនឹកស្ដាយដល់អារ្យធម៌និងវប្បធម៌ទាំងឡាយនោះ ដែលប្រសូតចេញមកអំពីខួរក្បាលរបស់អ្នកប្រាជ្ញទាំងឡាយដោយគម្រោងយ៉ាងនេះ, លោកខំព្យាយាមបីបាច់ថែរក្សាចិញ្ចឹមមកមានអាយុអស់រយៈវេលារាប់ពាន់ឆ្នាំ ទំរាំតែបានធំធាត់ឡើងបានប៉ុនសព្វថ្ងៃនេះ ។

ឯពួកលោកទាំងមូល កំពុងមានសេចក្ដីស្ញើចសរសើរដល់អារ្យធម៌និងវប្បធម៌ទាំងឡាយនោះពុំទាន់អស់ពុំទាន់ហើយ មានសេចក្ដីរីករាយត្រេកត្រអាលចំក្រេបជញ្ជក់នូវសេចក្ដីរុងរឿងគ្រប់បែបគ្រប់យ៉ាង ក៏ស្រាប់តែមកបានឮដំណឹងអកុសលអ៊ីយ៉ាងដូច្នេះ; នេះនាំឲ្យពួកលោកទាំងមូលមានសេចក្ដីព្រួយបារម្ភ និកស្ដាយស្រណោះដល់វិទ្យាសាស្ត្រទាំង-ឡាយ ដែលកំពុងតែចំរើនឡើងសព្វថ្ងៃនេះទុកជាមុន មានអ្នកខ្លះលាន់មាត់ចេញវាចាថា ឱ! កុមារកុមារីក្នុងសាកលលោកទាំងឡាយអើយ! បើគ្រឿងយុទ្ធសាស្ត្ររបស់គេ ចំរើននូវអានុភាពខ្លាំងក្លាយ៉ាងម្ល៉េះ

តើអនាគតរបស់អ្នកនឹងទៅជាយ៉ាងណាទៅ? ឱព្រះបរមរាជវាំងនិងហោ គេហដ្ឋានឬវត្ថុបុរាណផ្សេងៗ ដែលជាវិរុងរឿងក្នុងលោកនេះទាំងឡាយ អើយ! តើអនាគតរបស់នៃគ្រឿងលំអលោកទាំងឡាយនេះ នឹងទៅ ជាយ៉ាងណាទៅ? ឱក្បួនតម្រាដែលណែនាំសម្រាប់ដឹកនាំនៃអារ្យធម៌ នឹងវប្បធម៌ទាំងឡាយអើយ ដែលវត្ថុបុរសទាំងឡាយនោះខំគិតខំ សរសេរទុកមកប្រើឲ្យជួយការមនុស្សយ៉ាងដូច្នេះ! តើអនាគតរបស់ក្បួន តម្រាទាំងនោះនឹងទៅជាយ៉ាងណាទៅនេះ?

កាលណាបើបានឮដំណឹងអំពីអានុភាពនៃគ្រឿងយុទ្ធសាស្ត្រនោះ ឡើងហើយ នាំឲ្យយើងមានសេចក្ដីទុក្ខព្រួយស្ដាយស្រណោះ ដល់ អារ្យធម៌នឹងវប្បធម៌នោះទុកជាមុនឥតឧបមា ។

## ទំនួញសោកស្ដាយ

បទពាក្យ៧

ខ្ញុំឮដំណឹងឡើង ភ្ញាក់ស្មើងម៉ឺងញ័រអង្គា
ព្រួយផល់វត្ថុនានា ដែលកំពុងតែរុងរឿង ។
បរិបូណ៌ដោយវិជ្ជា: ទាំងអារ្យធម៌កើតឡើង
សព្វថ្ងៃកំពុងចំរើន ដោយស្នាដៃនៃអ្នកប្រាជ្ញ ។
ឥឡូវមកមានហេតុ ក្នុងចំណោទគ្រប់ក្ដីកំណាច
ផ្គងវិទ្ធឲ្យម្ចាស់ខ្លាច កាចនឹងកាចប៉ង់ល្បងគ្នា ។

ដណ្ដើមយកឈ្នះចាញ់ មានតែអញ្ចឹងលោកា
អ្នកអាងញាក់ដាក់គ្នា ឲ្យវេទនាដល់ពលលោក ។
សង្គ្រាមលើកទីពីរ មនុស្សវេរីស្លាប់គរគោក
ព្រោះតែដណ្ដើមជោគ ជ័យជំនះតែរៀងខ្លួន ។
ហិនហោចដល់ភោគទ្រព្យ មនុស្សក៏ស្លាប់រាប់ចំនួន
លានលានតែរៀងខ្លួន គិតចំនួនគួរស្ដាយណាស់ ។
អាសូរក្មេងកំព្រា គួរវេទនាដោយព្រាត់ប្រាស
ឪពុកម្ដាយវិនាស ខ្លះព្រាត់ប្រាសកូនប្រពន្ធ ។
បង្ហូរតែទឹកភ្នែក ខ្លះយំស្រែកដើររកគន់
ស្វែងរកកូនប្រពន្ធ ថែមទុក្ខធ្ងន់ឥតអត់បាយ ។
សង្គ្រាមផុតកាលណា តាំងនាំគ្នាអង្គុយស្ដាយ
ជីវិតទ្រព្យទាំងឡាយ ដែលវិនាសក្នុងសង្គ្រាម ។
អំណាចនៃលោភៈ កើតទោសៈមោហៈតាម
ប្រកិតបិទបាំងស្នាម ប្រាជ្ញាត្រូវយល់ថាខុស ។
ខ្ញុំសូមឧទកាយា ដល់ទេវតាជួយសន្ដោស
ឲ្យលោកផុតពីគ្រោះ នឹងសង្គ្រាមបរមាណូ ។

បុប្ផាយមិត្រហៀន ផុះឡើងផែនដីឆេះខ្ចី
សូមជួយឲ្យសុខយូរ រាប់ពាន់ឆ្នាំទៅមុខហោង ។
ខ្ញុំសូមទុកចិន្តា លើអង្គការជាតិជាម្ដង
សូមឲ្យជួយលោកផង កុំឲ្យមានសង្គ្រាមអើយ !!! ។

ខ្ញុំសូមលើកយកនូវសេចក្ដីសុខ និងការ ធម៌ ព្រមទាំងវឌ្ឍនធម៌ ក្នុងលោកទាំងមូលនេះ ផ្ញើទៅលើអង្គការសហប្រជាជាតិ គឺលោកនេះហើយដែលជាគ្រឿងក្រោះមួយយ៉ាងសំខាន់ សម្រាប់ហុំព័ទ្ធការពារនូវភ្លើងសង្គ្រាមលោកទៅអនាគត កុំបីឲ្យមានឆេះរាលដាលទៅលើសេចក្ដីសុខ ក្នុងលោកទាំងមូលនេះដែលជាទីជ្រកកោនដល់មនុស្សលោក ដែលកំពុងត្រូវការចង់ដឹងចង់ស្គាល់ចង់ឃើញដោយរីករាយ ។

ខ្ញុំសូមសង្ឃឹមទុកចិត្តលើអង្គការនេះហើយ ដែលមានសមាជិក ជាង កន្លះរយប្រទេសដែលនៅប្រចាំក្នុងអង្គការនេះ ទុកដូចជាគួអង្គទេវតាប្រចាំក្នុងរដ្ឋមួយ ៗ គឺលោកនេះហើយដែលជាអ្នកទទួលខុសត្រូវចំពោះលោកទាំងមូល, ហើយសូមទុកលោកជាទេវតាប្រចាំទិស សម្រាប់ការពារនូវសេចក្ដីវិនាសគ្រប់បែបគ្រប់យ៉ាង ហើយជាអ្នកស្វែងរកនូវសេចក្ដីសុខ មកឲ្យសាកលលោកទាំងមូលនេះផង ដូចជាក្នុងកាលថ្ងៃទី ២ ខែ មេសា ឆ្នាំ ១៩៥០នេះ មានប្រជាជាតិសណ្ដៅប្រហែលជា ៥០ នាក់ បាននាំគ្នាអត់អាហារប្រឆាំងនឹងគ្រាប់បែកបរមាណូ និងអ៊ីដ្រូហ្សែន ។

មានសាវកមហាត្មៈគន្ធីប្រហែលជា ៥០ នាក់ កើតសេចក្តីជ្រះថ្លាចំពោះសាកលលោក ហើយបាននាំគ្នាប្រកាសថា មានតែលទ្ធិអហិង្សា (ការមិនបៀតបៀនអ្នកដទៃ) មួយនេះទេ ដែលអាចនឹងនាំយកសេចក្តីសុខមកដាក់ក្នុងលោកនេះបាន ៗ ពួកនេះបានរួមចិត្តគ្នាអត់អាហារអស់រយៈវេលាមួយសប្តាហៈ គឺចាប់តាំងពីថ្ងៃទី ២ ដល់ថ្ងៃទី ៨ ខែមេសា ឆ្នាំ ១៩៥០ នេះ ប្រយោជន៍ដើម្បីនឹងប្រឆាំងដល់ជាតិណាដែលបំរុងនឹងធ្វើសង្គ្រាមទៅអនាគត ហើយប្រឆាំងនឹងគ្រាប់បែកអ៊ីត្រូហ្សែននឹងអាតូមិចនោះផង ៗ

ប៊ុន - ថាន់ អតីតតំណាងរាស្ត្រ

## ស្នេហ៍ជាតិពិតមិនស្តាយជីវិត

ស្នេហ៍ជាតិពិតត្រូវពិនិត្យដោយធម៌បី
មួយគឺក្តីព្យាយាមប្រកបកិច្ច
ពីរកាន់ទៀងរៀងរាល់ថ្ងៃទោះច្រើនតិច
បីបើកិច្ចមិនសម្រេចស៊ូមរណ៍អត្ត ៗ

តែក្នុងជំពូកទាំង ៣ នេះ
បើនឹងរករកគុណាដែលខ្ពង់
ធម៌ទី ៣ ធំខ្ពង់ជាងទ្រទ្រង់
ធម៌ ២ ពីរទៀតផង់ផង់កើតមានបាន ៗ

យូរ – អ៊ុន

La Lumières de l'Asie

# លោកស៊ែរ-អេតវិនអារណុលដ៍ តែង

លោកកយ-ប៊ុក ក្រមការ ប្រែរៀបរៀង

( ៣៦៣ )

មានពពែញីមួយមានសម្បុរខ្មៅៗ មានស្នែងវែង ដេកសន្ធឹងនៅដីមានក្បាលគេចងភ្ជាប់នឹងស្មៅមុញ្ជា[1] (Moudja); -មានព្រាហ្មណ៍ម្នាក់យកកាំបិតផ្ទាប់នឹងកសត្វនោះហើយសូត្រធម៌ខ្សឹបៗ ថា "ឱព្រះដែលមានឥទ្ធានុភាព! នេះហើយជាយ័ញ្ញភាស[2] (yadjaras) ដែលព្រះបាទពិម្ពិសារ (Bimbisara) យកមកបូជា; អ្នកចូរត្រេកអរ ដោយការឃើញលោហិតហូរចុះ, អ្នកចូរមានចិត្តរីករាយសប្បាយ ដោយការឃើញសាច់មានខ្លាញ់ដែលគេមកចំអិននឹងភ្លើងចុះ, បាបអកុសលដែលព្រះមហាក្សត្របានធ្វើ សូមឲ្យធ្លាក់ទៅលើពពែញីនេះ ហើយសូមឲ្យភ្លើងឆេះរំលាយសត្វនេះទៅចុះ, ខ្ញុំនឹងសម្លាប់សត្វនេះក្នុងកាលឥឡូវនេះ" ។

តែព្រះពោធិសត្វទ្រង់មានព្រះបន្ទូលថា: "ឱព្រះសម្មតិទេព, កុំឲ្យគេពិឃាតកាត់ធ្វើអី" ដល់មានព្រះបន្ទូលដូចនេះរួច ព្រះអង្គបានស្រាយ

---

១ មុញ្ជាជាភាសាឥណ្ឌា គឺជាឈ្មោះសម្រាប់ហៅស្មៅមួយបែប ដែលមានដុះនៅប្រទេសឥណ្ឌា ហើយសម្រាប់យកមកធ្វើវេញជាខ្សែ ។ ២ យ័ញ្ញរស ប្រហែល យញ្ញ (Yajna) ទេ ព្រោះក្នុងពិធីនេះគេយកសត្វទៅធ្វើពលិកម្ម ។

ចំណងដែលចងភ្ជាប់នោះចេញ ។ ក្នុងពេលនោះ គ្មានអ្នកណាហាមឃាត់ព្រះអង្គឡើយ ព្រោះព្រះអង្គមានព្រះកាយការដ៏អស្ចារ្យ គួរឲ្យជនទាំងពួងគោរពកោតក្រែង ។

ព្រះពោធិសត្វបានសូមទោសព្រះមហាក្សត្រ ហើយមានព្រះបន្ទូលថា: "ជីវិតរបស់ជនគ្រប់រូបៈគេអាចយកចេញបាន តែមិនមានអ្នកណាអាចឲ្យបាន ; ជីវិតគឺពួកសត្វទាំងអស់ក្នុងសាកលលោកតែងស្រឡាញ់ ហើយមានចិត្តតស៊ូចំពោះសត្រូវព្រោះតែជីវិតនេះ ; ជីវិតជាវត្ថុប្រកបដោយអច្ឆរិយវត្ថុថ្លៃហើយជាទីពេញចិត្តចំពោះជនទាំងពួងគ្រប់រូប រហូតដល់សាមញ្ញសត្វ ; មែនហើយ ជីវិតគឺជាអំណោយដ៏ថ្លៃថ្លាចំពោះសត្វលោកដែលមានចិត្តមេត្តា ព្រោះចិត្តមេត្តានេះ ធ្វើឲ្យសត្វលោកស្លូតត្រង់ចំពោះសត្វណាដែលទុព្វលភាព ហើយធ្វើឲ្យវិសេសវិសាលចំពោះសត្វណាដែលមានកំឡាំងជាងគេ" ។ ព្រះពោធិសត្វទ្រង់ជាអ្នកតំណាងពួកសត្វដែលមានមាត់មិនចេះស្តីនិយាយ ព្រះអង្គមានព្រះបន្ទូលជួសសត្វទាំងនេះ ដោយព្រះប្រយ័កវាចាដ៏ទន់ផ្អែមល្ហែម ដើម្បីនឹងតវ៉ាចំពោះព្រះកត្រ្តព្រះមហាក្សត្រ ; ព្រះអង្គទ្រង់បង្ហាញឲ្យឃើញថា : "មនុស្សដែលសូមឲ្យព្រះសន្តោសត្រាប្រណីទោសនោះ ជាអសារឥតការ ព្រោះមនុស្សៈនោះជាព្រះរបស់សត្វតិរច្ឆានទៅហើយ, តែវត្ថុដែលមានជីវិតក្នុងលោកតែងមានក្រសែភាក់វង់គ្នាដោយញាតិសាច់លោហិត ហើយ

សត្វដែលយើងពិឃាតទាំងនោះគឺជាសត្វដែលបានឲ្យទឹកដោះគោ, ទៀ ទុណ្ណាម័យដល់យើង ហើយក៏បានទុកចិត្តប្រគល់ជីវិតឲ្យយើងដែលមានបំណងនឹងសម្លាប់" ដូច្នេះហើយ ព្រះអង្គមានព្រះបន្ទូលអំពីសៀរគោធម៌ផ្សេងៗ ដែលបានសំដែងដោយជាក់ច្បាស់ថា: "ក្រោយដែលសត្វអនិច្ចកម្មទៅ មិនថាយើងឬគេទេ ខ្លះត្រូវទៅចាប់កំណើតជាបក្សា, សត្វតិរច្ឆាន, ខ្លះជាមនុស្សជាតិគឺជាភ្លើងដែលធ្វើដំណើរតាមអាកាស ប្រែសភាពទៅជាភ្លើងបរិសុទ្ធស្អាតទៅវិញ ព្រោះហេតុដូចនេះ ពលិកម្មនេះជាកម្មមួយថ្មីទៀត បើឃាត់ហាមមិនឲ្យព្រលឹងទៅចាប់កំណើតតាមជោគវាសនាសត្វៗ ខ្លួន ៗ មិនមានអ្នកណាយកលោហិតមកធ្វើឲ្យប្រាជ្ញាមានសភាពបរិសុទ្ធស្អាតទេ; បើព្រះ,ទេវតានឹងព្រះព្រហ្មនោះចិត្តល្អ, លោហិតទាំងនេះមិនមែនធ្វើឲ្យលោកទាំងនោះមានហសនចិត្តទេ បើព្រះទាំងនោះមានសន្តានចិត្តកាច, លោហិតនេះមិនធ្វើឲ្យប្រែចិត្តគំនិតបានទេ ។ គេមិនអាចយកបាបកម្ម ១ បំរៀកសក់ដែលត្រូវទទួលផលចំពោះខ្លួន មកដាក់លើក្បាលសត្វដែលឥតប្រព្រឹត្តខុសបានឡើយ ព្រោះបុគ្គលម្នាក់ៗត្រូវទទួលដំពាក់ចំពោះខ្លួនតាមច្បាប់លេខគណិតនៃលោកធាតុ ដែលពោលថា: ·អ្នកធ្វើល្អនឹងបានល្អ, អ្នកធ្វើអាក្រក់នឹងបានអាក្រក់ តាមការប្រព្រឹត្តដោយកាយ-វាចា ឬចិត្ត: ច្បាប់ដែលមានសភាពពិត មិនចេះយោគយល់ដោយអគតិ មិនចេះប្រែប្រួល ហើយថ្លែងថា "អនាគតហេតុជាផលនៃអតីតហេតុ" ។

(មានត)

# ពលគាថា

## ព្រះទេពមុនី យូរ - ប៊ុណ្ណ

ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

(គ - ចប់)

---

ជនអ្នកមានសទ្ធា រមែងបានអានិសង្ស ៥ យ៉ាងគឺ :-

១ - បឋមំ អនុកម្បន្តិ សប្បុរសទាំងឡាយតែងអនុគ្រោះ ដល់អ្នកមានសទ្ធាមុនគេ ។

២ - បឋមំ ឧបសង្កមន្តិ សប្បុរសទាំងឡាយតែងចូលទៅរក អ្នកមានសទ្ធាមុនគេ ។

៣ - បឋមំ បដិគ្គណ្ហន្តិ សប្បុរសទាំងឡាយតែងទទួលយក ទេយ្យវត្ថុរបស់ជនអ្នកមានសទ្ធាមុនគេ ។

៤ - បឋមំ ធម្មំ ទេសេន្តិ សប្បុរសទាំងឡាយរមែងសំដែង ធម៌ដល់ជនអ្នកមានសទ្ធាមុនគេ ។

៥ - សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ជនអ្នកមានសទ្ធានោះ លុះធ្វើមរណកាលហើយ រមែងទៅកើតក្នុងសុគតិភពគឺស្ថានសួគ៌ ។

ពោលមកប៉ុណ្ណេះ ហៅថា សទ្ធាពលៈ ។

៣) **វីរិយពលៈ** ប្រែថា "កំឡាំងគឺសេចក្ដីព្យាយាមៈ" ។ សេចក្ដីព្យាយាមនេះជាគុណជាតិមួយ៉ាង ដែលយឹតយោងចិត្តឲ្យមានកំឡាំងក្នុងការប្រព្រឹត្តធម៌ ឬប្រកបការងារគ្រប់យ៉ាង, បើទុកជាមានជំនឿយ៉ាងណាក៏ដោយ តែបើខ្វះសេចក្ដីព្យាយាមហើយ ការជឿនោះ ក៏មិនបានកំឡាំងប៉ុន្មាន ។.

សេចក្ដីព្យាយាមនេះ បើពោលដោយសង្ខេបមានពីរយ៉ាងគឺ:

១– **បហានៈ** ព្យាយាមលះសេចក្ដីអាក្រក់កុំឲ្យកើតឡើងក្នុងសន្ដាន ។

២– **ភាវនា** . ព្យាយាមធ្វើកុសលឲ្យកើតឲ្យមានឡើងក្នុងសន្ដាន ។

សេចក្ដីព្យាយាមនេះ កាលបើបុគ្គលបានធ្វើហើយ ប៉ុន្ដែមិនថែរក្សាសេចក្ដីល្អទុក, សេចក្ដីល្អនោះ ក៏នឹងវិនាសទៅវិញ, ព្រោះសេចក្ដីល្អមិនមែនជារបស់គួរធ្វើម្ដងម្កាលឡើយ គួរធ្វើជានិច្ច ទើបឈ្មោះថាមានសេចក្ដីល្អប្រចាំនៅក្នុងសន្ដាន ឬក៏ព្យាយាមរក្សាសេចក្ដីល្អដែលបានធ្វើម្ដងនោះ ហើយមិនធ្វើតទៅទៀត សេចក្ដីល្អនោះក៏ខ្សោយកំឡាំងថយតិចទៅវិញ. កាលបើសេចក្ដីព្យាយាមមានកំឡាំងមាំមួនហើយ ក៏រមែងដូចជាប្រឡាយហូរទៅរកសេចក្ដីចំរើន, សូម្បីការងារឬផ្លូវប្រតិបត្តិនោះ ទោះ

ក្រលំបាកយ៉ាងណាក៏ដោយ គង់បានសម្រេចដូចបំណង ។ សូមទាញឧទាហរណ៍មកបន្តិចឲ្យឃើញកំឡាំងនៃសេចក្ដីព្យាយាម ; ដូចមហាសមុទ្រដែលមើលកោះមើលត្រើយមិនឃើញ ផុតវិស័យមនុស្សសាមញ្ញនឹងគិតលៃលកកេប្រយោជន៍ឲ្យកើតដល់ខ្លួនមិនបាន, តែគង់មានមនុស្សអ្នកមានគំនិតប្រាជ្ញា អាចគិតឃើញ គេធ្វើនាវាធំតូចប្រកបដោយគ្រឿង ឬគ្រឿងចក្រគ្រឿងយន្ត ហើយផ្ទុកទំនិញគ្រប់យ៉ាង បើកកាត់ឆ្លងទៅមកលក់ដូរគ្រប់ប្រទេសក្នុងលោក យកមាសប្រាក់ភ័ស្តុភារមកជាប្រយោជន៍ខ្លួន ឬយកមកកសាងប្រទេសរបស់គេ ឲ្យទៅជាអារ្យប្រទេសបាន ។

មួយទៀត ដូចយ៉ាងមនុស្សជាន់ខ្ពស់ក្ដី ស្ថានសួគ៌ក្ដី ស្ថានព្រហ្មក្ដី ព្រះនិព្វានក្ដី សុទ្ធតែជាកន្លែងជាន់ខ្ពស់ គេក្របានជួបប្រទះ ក្របានទៅកើតណាស់ ; តែបើទុកជាដូច្នោះ ក៏គង់មានបុគ្គលអ្នកព្យាយាមចំប្រឹងធ្វើប្រឹងប្រព្រឹត្តត្រាតែបានទៅកើតទៅនៅរាប់មិនអស់, មើលចុះដូចយ៉ាងព្រះមហាក្សត្រនឹងមន្ត្រីសេដ្ឋីគហបតីតូចធំ នឹងពួកទេវតា ពួកព្រហ្ម ឬព្រះអរហន្តទាំងឡាយមានព្រះពុទ្ធជាដើម ដែលទ្រង់បានសម្រេចដល់ឋានតាមលំដាប់ទាំងនោះ ក៏ព្រោះសេចក្ដីព្យាយាមអប់រំកំឡាំងចិត្តឲ្យប្រព្រឹត្តទៅក្នុងកុសលធម៌តាមជាន់តាមថ្នាក់ដែលគួរធ្វើគួរប្រព្រឹត្តបាន; យ៉ាងនេះហៅថា វីរិយពលៈ ។

**៣) សតិពលៈ** ប្រែថា "កំឡាំងគឺសតិ" ។ សតិនេះ ជាគូគ្នានឹងសម្បជញ្ញៈ, សតិនឹងសម្បជញ្ញៈជាធម៌មានឧបការច្រើន ។ សតិ ប្រែថា "សេចក្ដីរលឹក" ។ សម្បជញ្ញៈ ប្រែថា "សេចក្ដីដឹងខ្លួន" ។ គុណធម៌ទាំងពីរនេះ ប្រព្រឹត្តទៅក្នុងកិច្ចជាមួយគ្នា ផ្សេងគ្នាតែអាការៈ; សតិជាភ្នាក់ងារខាងឯនឹកឃើញក្នុងវេលាដែលធ្វើហើយ និយាយហើយ គិតហើយ, សូម្បីយូរៗ ក៏នឹកឃើញបានទាំងអស់ ។ សម្បជញ្ញៈជាភ្នាក់ងារខាងឯដឹងខ្លួនក្នុងវេលាដែលកំពុងធ្វើ កំពុងនិយាយ កំពុងគិត ។ ចិត្តរបស់យើង កាលបើមិនមានសតិសម្បជញ្ញៈគ្រប់គ្រងហើយ តែងតែស្ទុះស្ទាធ្លេធ្លាអន្ទះអន្ទែងទៅរកវិសភាគារម្មណ៍ផ្សេងៗ តាមតែប្រទះ មិនរើសថាគួរនឹងមិនគួរឡើយ ។ ដូចជារថទឹមដោយសេះដែលមិនមាននាយសារថីបរ សេះបេះតែអូសរថទៅតាមទំនើងចិត្តរបស់វា ស្ទុះទៅផ្ដេសផ្ដាសប៉ះនេះប៉ះនោះហែៗ ទៅតាមផ្លូវ ធ្វើឲ្យកើតសេចក្ដីអន្តរាយផ្សេងៗ យ៉ាងណាមិញ; ឯសេចក្ដីប្រព្រឹត្តរបស់មនុស្សក៏ដូចគ្នា គឺថាមនុស្សម្នាក់ៗ បើមិនមានសតិសម្បជញ្ញៈហើយ រមែងប្រព្រឹត្តកាយវាចាខុសៗ ភ្លាត់ៗ ធ្វើឲ្យកើតសេចក្ដីអន្តរាយផ្សេងៗ ដល់ខ្លួននឹងអ្នកដទៃពុំខាន ។ ចំណែកមនុស្សដែលមានសតិសម្បជញ្ញៈវិញ រមែងប្រព្រឹត្តកាយវាចាតាមផ្លូវដែលល្អៗ ជាហេតុនាំឲ្យបានសេចក្ដីសុខចំរើនដល់ខ្លួននឹងអ្នកដទៃ ៖ យ៉ាងនេះ ហៅថា សតិពលៈ ។

៥) សមាធិពលៈ ប្រែថា "កំឡាំងគឺសមាធិ" ។ សមាធិ ប្រែថា "សភាពនឹងធឹង, ខ្ជាប់ខ្ជួន, មាំមួន" ។ សមាធិនេះ ជាធម៌សម្រាប់ពត់ចិត្តប្រែងចិត្តឲ្យតាំងនៅដោយល្អក្នុងអារម្មណ៍តែមួយ ព្រោះចិត្តនេះតែងត្រេកត្រអាលទៅក្នុងអារម្មណ៍ផ្សេងៗ មានរូបារម្មណ៍ជាដើម ។ ចិត្តនេះនៅមិនស្ងៀមទេ, ដូចជាសត្វស្វា ធម្មតាសត្វស្វាជាសត្វពើសណាស់ នៅមិននឹងមិនស្ងៀម ចាប់នេះចាប់នោះតាមតែប្រទុះ, កាលបើគេចងដៃជាប់ហើយ ក៏យកជើងទៅលូកចាប់ទៀត, កាលបើជាប់ជើងយកមាត់ទៅខាំទៀត, កាលបើជាប់មាត់ ចំផ្លូលប្រមះនទៀលខ្លួនឲ្យទៅប៉ះនឹងវត្ថុនោះទៀត ធ្វើដូចម្តេចឲ្យតែបានទៅប៉ះពាល់ ទោះបីវត្ថុនោះក្តៅត្រជាក់រឹងទន់ ល្អិតគ្រោតគ្រាត ក៏មិនធុញទ្រាន់ យ៉ាងណាមិញ; ចិត្តរបស់មនុស្សក៏ដូចគ្នាដែរ, កាលបើមិនមានសមាធិចិត្តនៅគ្រប់គ្រងហើយ ក៏រមែងធ្វេធ្វាស្ទុះស្ទាទៅឆបក្រសោបយកអារម្មណ៍ផ្សេងៗ តាមតែប្រទះ ធ្វើឲ្យគករល្អក់ ដល់ធម៌ដែលធ្លាប់បានអប់រំទុកមក ។ ព្រោះហេតុនោះ បុគ្គលគួរដំកល់ចិត្តឲ្យនឹងឲ្យស៊ប់ទៅក្នុងសមាធិធម៌ ទើបជាចិត្តស្ងប់ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ទាំងឡាយមាននីវរណធម៌ជាដើម ហើយក៏បានដល់បឋមជ្ឈាន, ទុតិយជ្ឈាន, តតិយជ្ឈាន តាមលំដាប់ដល់ចតុត្ថជ្ឈាន ដែលមិនមានទុក្ខមិនមានសុខ មានតែសតិដ៏បរិសុទ្ធដោយឧបេក្ខា ហើយចិត្តក៏ធ្ងន់ធុតចាកភពទាំង ៣ បានដល់ព្រះនិព្វាន ឥតមានការកើតសាប់តទៅៈ យ៉ាងនេះហៅថា សមាធិពលៈ ។

៥ បញ្ញាពលៈ ប្រែថា "កំឡាំងគឺបញ្ញា" ។ បញ្ញានេះជាធម្មជាតិដែលមានប្រចាំនៅក្នុងសន្តានតាំងពីកំណើត ទោះបីតិចច្រើនតាមឧបនិស្ស័យដែលបានអប់រំទុកមក ។ បញ្ញានេះជាគុណជាតិមិនញាប់ញ័រក្នុងអវិជ្ជា អាចជួយឧបត្ថម្ភនូវសហជាតធម៌ទាំងពួងឲ្យមានកំឡាំង ហើយញុំាងបុគ្គលឲ្យស្ថិតនៅក្នុងសេចក្តីសុខគឺព្រះនិព្វាន ។ បញ្ញានេះមានការជួយដោះទុក្ខដោះកុនដែលកើតឡើងក្នុងបច្ចុប្បន្ននេះភ្លាមៗបាន ។ បញ្ញានេះមានការដឹងប្លែកជាងសញ្ញានិងវិញ្ញាណ ។ សញ្ញាគ្រាន់តែដឹងនូវអារម្មណ៍មានពណ៌ខៀវលឿងជាដើម, មិនអាចចាក់ធ្លុះនូវត្រៃលក្ខណ៍បានឡើយ ឬក៏ដឹងនូវវត្ថុមានតម្លៃល្អអាក្រក់បានឡើយ ។ វិញ្ញាណដឹងច្បាស់នូវអារម្មណ៍មានពណ៌ខៀវលឿងជាដើមផង ចាក់ធ្លុះនូវត្រៃលក្ខណ៍ផង, តែមិនអាចឲ្យសំរេចមគ្គផលបានឡើយ ។ ឯបញ្ញាអាចដឹងច្បាស់នូវអារម្មណ៍គ្រប់យ៉ាង ទាំងចាក់ធ្លុះនូវត្រៃលក្ខណ៍ និងអាចជ្រោមជ្រែងឲ្យបានសម្រេចមគ្គផលគឺព្រះនិព្វានផង ។

ឯផ្លូវប្រតិបត្តិរបស់បញ្ញា ដែលព្រះពុទ្ធជាអ្នកប្រាជ្ញទ្រង់ត្រាស់សំដែងដោយច្រើននោះ បានខាងបញ្ញាដែលដឹងច្បាស់ក្នុងលក្ខណៈ ៣ យ៉ាងគឺ អនិច្ចតា=សភាពជារបស់មិនទៀង ១, ទុក្ខតា=សភាពជាទុក្ខ ១, អនត្តតា = សភាពមិនមែនជារបស់ខ្លួន ១ ។ ទាំងបីនេះជាផ្លូវប្រតិបត្តិនៃបញ្ញា អាចយល់ច្បាស់នូវការកើតឡើងនិងវិនាសទៅវិញ ហើយអាច

ចាក់ធ្លុះទំលុះទំលាយនូវគំនរនៃលោភៈ ទោសៈ មោហៈ ឲ្យអស់ទៅ ជាបញ្ញាបរិសុទ្ធផុតចាកកិលេស ហើយធ្វើវដ្តទុក្ខឲ្យអស់ទៅដោយប្រពៃ ។ បញ្ញាចែកចេញជា ២ យ៉ាងគឺ លោកិយបញ្ញា ១ លោកុត្តរបញ្ញា ១ ។ បញ្ញាឈ្លាសវាងវៃ ស្គាល់ហេតុ-ផល ចេះរក្សាខ្លួនឲ្យបានសុខស្រួលក្នុងបច្ចុប្បន្ន ហៅថា លោកិយបញ្ញា ។ បញ្ញាដែលខ្ពង់ផុតលោកទាំងបី ហៅថា លោកុត្តរបញ្ញា ។

បញ្ញានេះទុកដូចជាអាវុធមុតថ្វា អាចកាប់ឆ្ការនូវព្រៃទ្រុបទ្រុលគឺកិលេសដែលធ្វើចិត្តសត្វឲ្យសៅហ្មង , ឬ ដូចជាប្រទីបសម្រាប់បំភ្លឺក្នុងទីងងឹត ។

ហេតុឲ្យកើតបញ្ញាមាន ៣ យ៉ាងគឺ :

១ – **សុតាមយប្បញ្ញា** បញ្ញាកើតអំពីការស្តាប់ ។

២ – **ចិត្តាមយប្បញ្ញា** បញ្ញាកើតអំពីការគិត ។

៣ **ភាវនាមយប្បញ្ញា** បញ្ញាកើតអំពីការចំរើនភាវនា ឬការធ្វើឲ្យហ្វឹក ។ ទាំង ៣ នេះជាឧបាយធ្វើឲ្យកើតបញ្ញា ។

បុគ្គលអ្នកស្រឡាញ់សេចក្តីសុខ ចំរើន គួរអប់រំបញ្ញាឲ្យកើតឲ្យមានឡើងក្នុងសន្តាន ដើម្បីនឹងបំពេញប្រយោជន៍របស់ខ្លួនឲ្យបានគ្រប់គ្រាន់ ទាំងបច្ចុប្បន្ន ទាំងបរលោក; ពោលមកដោយសង្ខេបប៉ុណ្ណេះ ហៅថាបញ្ញាពលៈ ។ **ចប់ភាគ២**

## អម្ពជាតក

យុន បណ្ណានុរក្ស ប៊ូ-ប៊ូ ទៅពុទ្ធសាសនបណ្ឌិត្យ

ប្រែរៀបរៀង

---

រឿងនេះ ព្រះបរមសាស្ដាទ្រង់ទេសនាក្នុងវត្តជេតពន ប្រារព្ធនឹងព្រាហ្មណ៍អ្នកប្រព្រឹត្តល្អម្នាក់ របស់ត្រកូលគហបតីនៅនគរសាវត្ថី ។ ព្រាហ្មណ៍នោះ មានចិត្តសទ្ធាជ្រះថ្លាក្នុងសច្ចធម៌ បានចូលមកឧបសម្បទជាភិក្ខុ ជាអ្នកព្យាយាមធ្វើសមណកិច្ចគ្រប់ប្រការ ប្រាសចាកពាក្យគ្រហានិន្ទាក្នុងការប្រតិបត្តិអាចារ្យទាំងឡាយ ដោយខំយកចិត្តទុកដាក់ក្នុងការចាត់ចែងអាហារនឹងការដងទឹកប្រើប្រាស់ទឹកឆាន់ ឧស្សាហ៍បោសសំអាតកុដិសាលាកន្លែងស្រង់ទឹកនិងទីផ្សេងៗ, ខ្វល់ខ្វាយក្នុងការប្រតិបត្តិធម៌វិន័យធំតូចទាំងពួង លោកចូលចិត្តបោសសំអាតរោងឧបោសថ កុដិលានសីមា ទីផ្លូវដើរទៅកាន់រោងឧបោសថ ទាំងឲ្យទឹកដល់មនុស្សអ្នកស្រេកផឹកផងទៀត ។ ព្រោះសេចក្ដីល្អដ៏ធំក្រៃលែងរបស់លោកនេះឯង បានជាពួកមហាជនប្រគេនចង្ហាន់ដល់លោកក្នុង ១ ថ្ងៃប្រាំរយថាសជានិច្ច, លាភសក្ការៈដ៏ថ្លៃថ្លានិងកិត្តិគុណក៏កើតឡើងដល់វត្តអារាម, សេចក្ដីរុងរឿងទាំងឡាយក៏កើតមានឡើងដោយសារភិក្ខុ ១ រូបនេះឯង ។

ថ្ងៃមួយ ក្នុងធម្មសភា ភិក្ខុទាំងឡាយអង្គុយជុំនុំគ្នាពណ៌នាគុណសេចក្ដីល្អរបស់ភិក្ខុនោះ ដែលជាអ្នកបាននាំមកនូវលាភសក្ការៈនិង

កិត្តិគុណ, ព្រមទាំងញុំាងជីវិតរបស់មនុស្សជាច្រើនឲ្យរស់នៅដោយសេចក្ដីសប្បាយរីករាយ ៗ សម្ដេចព្រះបរមសាស្ដាស្ដេចចូលមកក្នុងធម្មសភាហើយទ្រង់ត្រាស់សួរ, កាលភិក្ខុទាំងនោះ បានក្រាបទូលរឿងដែលបានសន្ទនាគ្នាហើយ, ព្រះអង្គក៏មានព្រះពុទ្ធដីកាថា ៖

ម្នាលភិក្ខុទាំងឡាយ ! ភិក្ខុនេះបានជាអ្នកសង្វាតឧហាតក្នុងការប្រតិបត្តិក្នុងនាទីរបស់ខ្លួនដោយពេញលេញ, មិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងអតីតកាល ឫសី ៥០០ រូបចិញ្ចឹមជីវិតរស់នៅបាន ដោយសារតែផ្លែឈើផ្សេងៗដែលកើតអំពីគុណគឺសេចក្ដីល្អរបស់ភិក្ខុនេះដែរ ។

កាលត្រាស់ដូច្នេះហើយ ក៏ទ្រង់ទេសនារឿងក្នុងអតីតកាលតទៅថា ៖

គ្រាមួយ កាលព្រះបាទព្រហ្មទត្តសោយរាជ្យក្នុងក្រុងពារាណសី, ព្រះពោធិសត្វសោយព្រះជាតិជាព្រាហ្មណ៍ នៅខាងផ្លូវឧត្តរទិស លុះចំរើនវ័យធំឡើង ទ្រង់លះលោកិយវិស័យចេញបព្វជ្ជា បានជាប្រធានរបស់ពួកឫសី ៥០០ រូប សំណាក់អាស្រ័យនៅត្រង់ជើងភ្នំ ។ គ្រានោះ ទឹកក្នុងជ្រោះភ្នំហិមាល័យប្រទេសរាំងស្ងួតអស់ ទឹកក្នុងស្ទឹងត្រពាំង បឹងបួរ អូរព្រែកទាំងពួងក៏រីងហួតអស់ដែរ សត្វព្រៃទាំងឡាយក៏កើតសេចក្ដីក្ដៅក្រហាយដោយសារស្រេកទឹក ។ តាបសបានឃើញសត្វទាំងនោះមានទុក្ខវេទនាដោយសេចក្ដីស្រេកទឹកដូច្នោះ ឫសី ១ អង្គក្នុងចំនួននោះបានកាប់រំលំឈើ ១ ដើម ហើយចោះលុងធ្វើជាស្នូកវែង រួចទៅដងទឹកដែល

លោកអាចស្វែងរកបាន យកមកដាក់ក្នុងស្រុកនោះទុកបម្រុងឲ្យហ្វូងសត្វទាំងនោះផឹក ។ ពួកសត្វនាំគ្នាមកផឹកទឹកនោះទាំងហ្វូងៗ ចេះតែផឹកគត់ឈប់ឈរ ទាល់តែតាបសអស់ឱកាសនឹងចេញទៅស្វែងរកបេះផ្លែឈើយកមកឆាន់ខ្លួនឯង ។ លោកមិនអើពើនឹងសេចក្ដីស្រេកឃ្លានរបស់លោក ៗ គិតតែពីខំដងទឹកយកមកដាក់ក្នុងស្រុកទុកឲ្យហ្វូងសត្វផឹក ឲ្យវាបាត់ស្រេក ។

ពួកសត្វទាំងនោះបានជំនុំគិតគ្នាថា "យើងនឹងតបស្នងសងគុណតាបសនេះ ព្រោះថាការដែលលោកបំពេញកិច្ចតាមសេចក្ដីត្រូវការរបស់យើងពលគ្នានោះ ទាល់តែលោកគ្មានឱកាសចេញទៅរកបេះផ្លែឈើយកមកឆាន់ខ្លួនឯង លោកមានសេចក្ដីស្រេកឃ្លានជាខ្លាំង យើងពលគ្នាគួរតែព្រមព្រៀងគ្នាចុះខសន្យាថា អ្នកណាមកផឹកទឹកក្នុងទីនេះ អ្នកនោះត្រូវយកផ្លែឈើបែបណាមួយមកប្រគេនឫសីនេះ" ។

ពួកសត្វទាំងអស់ក៏ព្រមព្រៀងគ្នាធ្វើតាមខសន្យានោះ សត្វគ្រប់រូបដែលមកផឹកទឹក បាននាំយកផ្លែស្វាយនឹងផ្លែឈើនានាមកប្រគេនឫសី ទាល់តែផ្លែឈើទាំងនោះសម្បូណ៌ពោរពាស បើផ្ទុករទេះបាន ២.៥០០ រទេះ, ពួកឫសីទាំង ៥០០ រូបឆាន់ឆ្អែតគ្រប់គ្នា ហើយនៅសេសសល់ជាច្រើនទៀត ។

ដោយហេតុមានផ្លែឈើសម្បូណ៌ហូរហៀរដូច្នោះ ព្រះពោធិសត្វប្រកាសថា "គុណគឺសេចក្ដីល្អរបស់បុគ្គលតែម្នាក់ប៉ុណ្ណោះ អាចបណ្ដាល

ឲ្យកើតមានអាហារសម្រាប់ពួកគណៈបរិភោគឆ្អែតគ្រប់គ្នាបាន, តាមពិតយើងទាំងឡាយត្រូវតែតាំងសេចក្ដីព្យាយាមឲ្យខ្ជាប់ខ្ជួន ក្នុងការបំពេញសេចក្ដីល្អនេះ" ។ កាលព្រះពោធិសត្វពោលដូច្នេះរួចហើយ ក៏បញ្ចេញឧទានគាថា ៖

អ្នកទាំងឡាយចូរខំប្រឹងប្រែង ស្វះស្វែងប្រយោជន៍សាធារណា
កុំខ្ជិលទម្រន់ហួសមាត្រា កុំយកសុខាតែខ្លួនមួយ ។
មនុស្សម្នាក់ធ្វើគុណគាប់ប្រពៃ អាចជួយអ្នកដទៃឲ្យផុតព្រួយ
បើអាក្រក់តែម្នាក់នាំព្លួយ ដល់ពួកជាមួយរាប់ពាន់ ។

ពាក្យនេះជាឱវាទរបស់ព្រះមហាសត្វ ទូន្មានដល់ពួកឫសីទាំងឡាយ ។

កាលព្រះបរមសាស្ដាទេសនាចប់ហើយ ទ្រង់សំដែងអតីតជាតិថា កុក្កុនេះ គឺឫសីអ្នកមានគុណធ្វើអំពើល្អក្នុងគ្រានោះ, ឯតថាគតគឺឫសីជាប្រធាននៃឫសីទាំងឡាយ ។

អម្ពជាតក ចប់

វីរិយេន ទុក្ខមច្ចេតិ

គេកន្លងផុតទុក្ខដោយព្យាយាម

ពិធីជូនដំណើរសម្តេចសង្ឃនាយក

ដែលនិមន្តទៅលង្កាទ្វីប

ពី

# ព្រះគ្រូសិរីសោភ័ណ កិម – តូ

ក្រុមជំនុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យរៀបរៀង

---

ពិធីជូនដំណើរសម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត សង្ឃនាយក គណៈមហានិកាយ វត្តឧណ្ណាលោម ក្រុងភ្នំពេញ ជាគណៈប្រតិភូកម្ពុជរដ្ឋ និមន្តទៅធ្វើសន្និសិទនៅលង្កាទ្វីប ពីក្នុងខែឧសភា ឆ្នាំ ១៩៥០ ដូចមានសេចក្តីរាយការតទៅនេះ ៖

## វិធីប្រសិទ្ធពរប្រគេនសម្តេច

កាលពីថ្ងៃទី ១៩ ឧសភា ១៩៥០ វេលាម៉ោង ១៩ ពួកពុទ្ធបរិសទ្យទាំងបព្វជិតទាំងគ្រហស្ថជាច្រើន មានព្រះតេជព្រះគុណព្រះពោធិវង្សជាប្រធាន បាននិមន្តនិងអញ្ជើញមកប្រជុំគ្នា ក្នុងវិហារវត្តឧណ្ណាលោម រៀបតាំងគ្រឿងសក្ការបូជានិងប្រទីបផ្កាលា ដំរេរជាសក្តិព្រោងព្រាតថ្វាយព្រះរតនត្រ័យ គួរឲ្យជាទីពិតពិលរមិលមើលជាយ៉ាង

ក្រៃលែង ៗ ក្នុងពិធីនោះ ព្រះសង្ឃដែលមានឋានន្តរស័ក្តិជាពជាគណៈ និងឋានានុក្រមជាច្រើនអង្គ បាននិមន្តមកគង់លើអាសនៈដ៏វិចិត្រដែលគេតាក់តែងយ៉ាងស្អាតបាតដើម្បីចំរើនព្រះបរិត្ត រួចហើយនិមន្តសម្តេចព្រះមហាសុមេធាធិបតី មកគង់លើអាសនៈពិសេសមួយដែលគេរៀបចំទុកប្រគេនជាមុន និមន្តព្រះគ្រូសង្ឃសត្ថា ប៉ុណ្ណ-សុក្កាជ អញ្ជើញឧបាសក ២ រូបទៀតគឺ បៅកៃ បេ-យាន និងលោកតាន់-ជូហេង ដែលជាអ្នកតាមអមជូនដំណើរសម្តេចរហូតទៅលង្កាទ្វីបដែរនោះ មកគង់និងអង្គុយលើអាសនៈ ជាលំដាប់ដោយឡែកចំពោះមុខព្រះសង្ឃ ៗ លុះព្រះសង្ឃចំរើនព្រះបរិត្តប្រសិទ្ធីពរចប់ហើយ ព្រះតេជព្រះគុណព្រះញាណវង្ស ពៅ-ទេត ជាតំណាងព្រះសង្ឃក្នុងពេលនោះ បានបញ្ចេញវាចាបួងសួងប្រសិទ្ធីពរជោគជ័យសិរីមង្គលគ្រប់ប្រការ ប្រគេនចំពោះសម្តេច និងព្រះគ្រូ ប៉ុណ្ណ-សុក្កាជ និងបៅកៃ បេ-យាន, លោក តាន់-ជូហេង ៗ

លំដាប់នោះ សម្តេចព្រះមហាសុមេធាធិបតីលើកព្រះហស្តប្រណម្យទទួលពរដោយសោមនស្សជាកិយ្យាភាព ៗ

ចំណែកខាងក្រុមឧបាសកឧបាសិកា មានព្រះតេជព្រះគុណអតីតរដ្ឋមន្ត្រី ស៊ុំ-ហ៊ីង ជាដើម ដែលអង្គុយត្រៀបត្រានៅទីនោះដែរ បានបញ្ចេញវាចាប្រគេនពរស័ព្ទសាធុការចំពោះសម្តេចតែរៀងខ្លួន ៗ ៗ

# ពិធីជូនដំណើរសម្តេចសង្ឃនាយក ទៅឡើងយន្តហោះនៅពោធិ៍ចិនតុង

ថ្ងៃទី ២០ ឧសភា ១៩៥០ វេលាព្រឹកម៉ោង ៨ ឃើញមានរថយន្តធំតូចឈប់ដេរដាសត្រៀបត្រា នៅតាមវិថីអូហ៊ុយេរពីខាងលិចវត្តនឹងតាមវិថីអែមេត្រង់ពីខាងជើងវត្ត នឹងតាមវិថីព្រះកដកាំងពីខាងមុខវត្តនឹងផ្លូវមួយខាងកើតវត្តឧណ្ណាលោម ។ រថយន្តនីមួយ ៗ ឃើញប្រើនតែពួកព្រះសង្ឃទីជាកជាគណៈធំ ៗ មានសម្តេចព្រះធម្មលិខិតទីឧត្តមប្រឹក្សានឹងព្រះតេជព្រះគុណព្រះពោធិវង្សជាដើម ព្រះសង្ឃទីជាឋានានុក្រមនឹងព្រះសង្ឃជាសិស្សសាលាបាលីជាន់ខ្ពស់ សាលាបាលីរងដែលនៅវត្តឧណ្ណាលោមខ្លះ ដែលចេញមកពីវត្តផ្សេង ៗ កងទីក្រុងខ្លះ ព្រមទាំងពួកគ្រហស្ថមកត្រៀមរង់ចាំជូនដំណើរសម្តេចតែសព្វ ១ ខ្លួន ១

ដំណើរនេះ គួរឲ្យស្ងើចណាស់, ពួកព្រះសង្ឃក្តី ពួកគ្រហស្ថក្តី ដែលជិះរថយន្តមកត្រៀមចាំជូនដំណើរទាំងប៉ុន្មាននោះ ឥតមានលោកណា ឬ អ្នកណាដើរឃោសនាបបួលដឹកនាំឲ្យធ្វើដូច្នេះឡើយ ស្រាប់តែបណ្តាលទឹកចិត្តទាំងព្រះសង្ឃទាំងគ្រហស្ថឲ្យមានសាមគ្គីរួមដំណើរស្រប ជាមួយគ្នាតែម្តង ។ លុះដល់ម៉ោង ៨ នឹង ២០ នាទី មានរថយន្តចំនួនជា ៥០ ទាំងធំទាំងតូច បើករត់ចេញបន្តដង្ហែគ្នាពីខាងមុខនៃរថយន្តសម្តេចព្រះមហាសុមេធាធិបតី តាមថ្នល់តីរវិថី (កេស៊ីសុវត្ថិ) លឿន

តម្រង់ទៅទិសខាងជើង, មានរថយន្តមួយក្រុមទៀតចំនួន ៣០ ដែរ បើកចេញដង្ហែបន្ទាប់ពីខាងក្រោយ នៃរថយន្តសម្តេចព្រះមហាសុមេធាធិបតី លុះដល់ទៅវិថីអង់ដួង ក៏បត់តម្រង់ទៅទិសខាងលិចសំដៅទៅពោធិ៍ចិនតុង, ស្រាប់តែឃើញមានរថយន្តតូចៗ គឺជារថយន្តនៃពួកបញ្ជិតខ្លះ ពួកគ្រហស្ថខ្លះ បើកបញ្ចូលទៅដង្ហែអមជូនដំណើរ ពីខាងមុខនិងពីខាងក្រោយនៃរថយន្តសម្តេចព្រះមហាសុមេធាធិបតីថែមទៀត ។

គ្រាពេលនោះ រថយន្តដែលបើកបន្ទាប់តាមថ្នល់ មានចំនួនកាន់តែច្រើនឡើងចំនួន ១០០ រថយន្ត ក្រឡេកមើលទៅរថយន្តខាងមុខនិងរថយន្តខាងក្រោយ ឃើញឆ្ងាយរលីមពីគ្នា ប្រហែលជា ១ គីឡូម៉ែត្រ ។ ចំណែកខាងពួកមហាជនប្រុសស្រី ដែលដើរទៅមកតាមចិញ្ចើមថ្នល់ទាំងសងខាង ក៏បញ្ឈប់ដំណើរនាំគ្នាឈរមើលស្រឡាំងកាំងគ្រប់គ្នា ។

ក្បួនរថយន្តដែលដង្ហែនោះ លុះដល់ទៅពោធិ៍ចិនតុងហើយ ក៏បត់ចូលទៅចតឈប់នៅត្រង់លានវាលមួយ, ទីលាននោះឯងក៏ចង្អៀតគាន់គាប់ទៅដោយរថយន្តធំតូច, ពួកព្រះសង្ឃទាំងអស់ចុះពីរថយន្តរៀងខ្លួនទៅនោះចំនួន ១.០០០ អង្គ ហើយគេនិមន្តឲ្យទៅឈរចាំជូនដំណើរនៅត្រង់លានវាលស្រឡះមួយពីខាងមុខយន្តហោះឈប់, ឯពួកគ្រហស្ថចំនួនជា ២០០ រូប ក៏នាំគ្នាទៅឈរចាំជូនដំណើរនៅត្រង់លានវាលមួយ ដោយឡែកអំពីពួកព្រះសង្ឃ ។

លុះដល់ម៉ោង ៩ ព្រះករុណា ជាម្ចាស់ជីវិតលើត្បូង, សម្តេចព្រះបរមរាជបិតា និងសម្តេចព្រះរាជជននីនាថព្រមទាំងគណៈរដ្ឋមន្ត្រីទ្រង់យាង និងអញ្ជើញទៅដល់ចំណតយន្តហោះនៅពោធិចិនតុងដែរ ដើម្បីជូនដំណើរជាព្រះកិត្តិយសចំពោះសម្តេចព្រះមហាសុមេធាធិបតី ។

លុះដល់ម៉ោង ៩ និង ២០ នាទី មុននឹងឡើងយន្តហោះ សម្តេចព្រះមហាសុមេធាធិបតី, ព្រះគ្រូសង្ឃសត្ថា ប៉ុណ្ណ សុម្ភាជ, ចៅកៃ បេយាន និងលោក តាន់-ដួហេង ទិមន្តនិងអញ្ជើញទៅចំពោះមុខព្រះសង្ឃចំនួន ១.០០០ អង្គនោះ ហើយសម្តេចមានព្រះពុទ្ធដីកាថា : ខ្ញុំករុណាអាត្មាភាពសុំលាហើយ! សូមឲ្យព្រះសង្ឃគ្រប់អង្គនិងទ្រង់អស់លោកនៅជាសុខសប្បាយចុះ! ។ ពួកព្រះសង្ឃនិងឧបាសកក៏ទទួលពរអំពីសម្តេចវិញថា សាធុព្រមគ្នា ។

ខណៈនោះ សម្តេចព្រះមហាសុមេធាធិបតី កំពុងបែរព្រះភក្ត្រនិមន្តសំដៅទៅឡើងយន្តហោះ ឯពួកព្រះសង្ឃក៏ចាប់សូត្រ ជយន្តោ . . . ប្រសិទ្ធិពរប្រគេនសម្តេចព្រះមហាសុមេធាធិបតី ។ ក្នុងខណៈនោះ មានឥស្សរជនជាន់ខ្ពស់ គឺព្រះករុណា ជាម្ចាស់ជីវិតលើត្បូង, សម្តេចព្រះបរមរាជបិតា, សម្តេចព្រះបរមរាជជននីនាថ, សម្តេចព្រះធម្មលិខិតទិឧត្តមប្រឹក្សា. និងព្រះតេជព្រះគុណព្រះពោធិវង្សជាដើម ទ្រង់ស្តេចយាងនិមន្តជូនដំណើរទៅដល់ជាប់ឡើងយន្តហោះ ។

លុះដល់ម៉ោង ៩ និង ៣០ នាទី គ្រឿងចក្ររបស់យន្តហោះ ក៏ដើរវិលខ្លាំងលាន់ឮសូរទ្រហឹងអឺងអាប់ ហើយក៏ស្ទុះលឿនស្មៅទៅទិសទក្សិណ, កាលហោះអណ្តែតផុតពីផែនដីឡើងហើយ ក៏បែរមុខសំដៅទៅក្រុងព្រៃនគរ ។ ពួកព្រះសង្ឃនិងពួកគ្រហស្ថ ឈរសំឡឹងមើលយន្តហោះ ដែលសម្តេចព្រះមហាសុមេធាធិបតីគង់នោះ ដរាបដល់ផុតគន្លងចក្ខុលែងមើលឃើញ ទើបនាំគ្នាឡើងជិះរថយន្តវិលត្រឡប់មកកាន់លំនៅរៀងៗខ្លួនវិញហោង ។

ព្រះស្រីសោភ័ណ

គាំ ម - ត្បូ

សុភាសិត

បំណេះវិជ្ជា និង សេចក្តីប្រព្រឹត្តិ ទាំង ២ នេះ
រមែងប្រោនមនុស្សឲ្យឡើងទៅកាន់ស័ក្តិយស
ជាន់ខ្ពស់បាន ដូចជាភ្នំដ៏ធំខ្ពស់ ។

យូ អ៊ុន

# បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី

## របស់ក្រសួងធម្មការ

(តមក)

សញ្ញាប័ត្រលេខ ៦៧០ ចុះថ្ងៃអង្គារ ៣ កើតខែអាសាឍឆ្នាំជូតឯកស័ក ព. ស. ២៤៩២ តាំងលោកគ្រូ ជោង-ចិត នាមឆាយា វិនយគ្រូ កើតឆ្នាំរកា អាយុ ២៨ វស្សា ៨, ជាគ្រូសូត្រស្តាំវត្តក្បាលដំរី ឃុំល្វែក ស្រុកដីក្រែង ខែត្រសៀមរាប ។

សញ្ញាប័ត្រលេខ ៦៧១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់-ពេជ្រ នាមឆាយា ញាណគ្រូ កើតឆ្នាំជូត អាយុ ២៥ វស្សា ៤ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៦៧២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ នង់-ទេព នាមឆាយា ព្រហ្មសិរី កើតឆ្នាំថោះ អាយុ ៣៥ វស្សា ១៥ ជាចៅអធិការវត្តព្រហូត ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៦៧៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ថន-ធូក នាមឆាយា ធម្មជោត កើតឆ្នាំរកា អាយុ ២៩ វស្សា ៦ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៦៧៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ព្រំ-យ៉ន់ នាមឆាយា ធម្មកេសរ កើតឆ្នាំមមែ អាយុ ៤៣ វស្សា ២១ ជាចៅអធិការវត្តតាគកាន ឃុំព្រះធាតុ ស្រុកកំពង់ត្របែក ខែត្រព្រៃវែង. ។

សញ្ញាប័ត្រលេខ ៦៧៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ តំ-តាំ នាមឆាយា សិរីវណ្ណោ កើតឆ្នាំមមែ អាយុ ៣១ វស្សា ៦ ជាគ្រូសូត្រឆ្វេង វត្តឃុំកំពង់ក្ដុក ស្រុកស្ទឹងត្រែង ខេត្តសៀមរាប ។

សញ្ញាប័ត្រលេខ ៦៧៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ លាក់-ប៊ូ នាមឆាយា ធម្មកេសរ កើតឆ្នាំមមែ អាយុ ៥៥ វស្សា ៧ ជាចៅអធិការវត្តត្រពាំងគ្រួស ឃុំកំពង់ត្រាច ស្រុករមាសហែក ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ៦៧៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ស៊ុក-អុក នាមឆាយា ធម្មជោត កើតឆ្នាំឆ្លូវ អាយុ ៤៩ វស្សា ២៨ ជាចៅអធិការវត្តកណ្ដាល ឃុំកែ្សត្រ ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ៦៧៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មាស-ឥន្ទ នាមឆាយា ពុទ្ធបញ្ញោ កើតឆ្នាំជូត អាយុ ២៦ វស្សា ៥ ជាគ្រូសូត្រស្ដាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ១៣៩ ចុះថ្ងៃសុក្រ ៦ កើតខែអាសាឍឆ្នាំឆ្លូវឯកស័ក ព.ស. ២៤៩២ តាំងលោកគ្រូ មាឃ-ស៊ូ នាមឆាយា សុវណ្ណត្ថេរ កើតឆ្នាំមមី អាយុ ៣២ វស្សា ១១ ជាចៅអធិការវត្តដំរីស ឃុំចៀប ស្រុកទឹកផុះ ខេត្តកំពង់ឆ្នាំង ។ (មានត)

ពុទ្ធសាសនបណ្ឌិត្យ សូមជូនដំណឹងជាថ្មីដល់ពុទ្ធបរិស័ទទាំងឡាយ ។ ដ្បិតការបោះពុម្ពព្រះត្រៃបិដកឡើងវិញនោះ យើងបានរៀបចំបោះជាសៀវភៅចែកជាពីរ កាលពីថ្ងៃទី ៤ សីហា ឆ្នាំ ១៩៨០ គឺ ១) ចាប់បោះសារឡើងវិញតាំងពីសៀវភៅទី ១-២ រហូតទៅដល់សៀវភៅទី ៣៥; ២) បោះបន្តពីសៀវភៅទី ៣៦-៣៧ រហូតដល់ចប់ ។

ឥឡូវនេះ ការបោះពុម្ពនោះ មានដំណើរជឿនទៅមុខក្រៃលណាស់ហើយ ទាំងពួកពុទ្ធបរិស័ទឡើងទៀតក៏ឃើញមានទៅចុះឈ្មោះជាវជាបន្ត ៗ គ្នាតែរាល់ ៗ ថ្ងៃ មានចំនួនច្រើនណាស់ដែរហើយ តែមិនទាន់អស់ ។

ហេតុនេះ បានជាយើងនឹកស្មានក្រែងនៅមានអស់លោក-អ្នកដែលចង់ជាវ ហើយមិនទាន់ចុះឈ្មោះជាវនោះ សូមអញ្ជើញទៅចុះឈ្មោះជាវ នៅមន្ទីរពុទ្ធសាសនបណ្ឌិត្យដោយរួសរាន់ ទាន់ក្នុងពេលឆាប់ៗនេះ ដើម្បីយើងអាចនឹងកំណត់ចំនួនសៀវភៅបោះពុម្ពជាមុន ហើយលៃប្រមាណឲ្យបានត្រឹមត្រូវតាមចំនួនឈ្មោះដែលចុះជាវ កុំឲ្យមានខ្វះខាតដល់អស់លោក-អ្នកឯណាដែលប្រាថ្នាចង់ជាវសៀវភៅនោះ ព្រោះយើងនឹងកំណត់ចំនួនសៀវភៅនោះឲ្យច្រើនទុកបង្ការទៅមុខមិនកើត ។

ពុទ្ធសាសនបណ្ឌិត្យ